A MONTHLY CAMBODIAN
ENTERTAINMENT & LIFESTYLE GUIDE
FREE!
ISSUE #39/AUG 2015
SCAN HERE FOR
UPDATE INFOMATION
Think
OUTSIDE
THE BOX
Hang Over សិល្បៈថតរូបថ្មីពី Professional
Photographer CHAN DEM
បណ្តែតខ្លួនទៅលើអាកាស
និងផ្ទៃទឹកសមុទ្របានតាមជំនោរខ្យល់សមុទ្រកម្ពុជា
KITE SURFING BOARD
SAILING
ជិះទ្បានកង់ធំៗ
4WD ADVENTURE
THE
240
RESTAURANT

ISSUE 39

36
CAPTURE WITH EMOTION

4WD CAMBODIA ADVENTURE

10

22
THINK OUT OF THE BOX

KITE BOARDING

12

28
CAMBODIAN YOUNG FASHION DESINGER

HIKING

06

EDITOR NOTE

ឡើងដើមឈើជាជំនាញ ដ៏ប៉ិនប្រសប់ជាងគេក្នុងចំណោមសកម្មភាពកម្សាន្តទាំងអស់ ដែលខ្ញុំចូលកាលពីនៅក្មេងព្រោះពេលឈរលើចុងឈើ ខ្ញុំអាចមើលឃើញទេសភាពប្លែកៗ ដែលខុសពីភ្នែកយើងពេលមើលពីផ្ទាល់ដី។ និយាយដល់ចំណុចនេះប្រហែលជាមិត្តអ្នកអានមួយចំនួនក៏គិតដូចខ្ញុំដែរ តែក៏មានអ្នកខ្លះទៀតមិនគិតដូចខ្ញុំ ឬក៏មិនធ្លាប់ឡើងដើមឈើខ្ពស់ៗទេ ព្រោះខ្លាចធ្លាក់មកដីបង្កជាបញ្ហាផ្សេងៗដល់គ្រួសារ។

អាចនិយាយថាខ្ញុំជាក្មេងក្បាលរឹង! ពុកម៉ែខ្ញុំតែងតែហាមមិនឲ្យដើរលេងនៅក្រៅផ្ទះញឹកញយទេ ព្រោះខ្លាចមានគ្រោះថ្នាក់ផ្សេងៗ។ ជាការពិតណាស់ រាល់សកម្មភាពកម្សាន្ត Outdoor ទាំងអស់ដែលយើងលេងកាលពីក្មេង អាចនឹងមានផលអាក្រក់មួយចំនួនមែន តែបើយើងគិតផ្ទុយពីនេះវិញ ដូចជារឿងឡើងដើមឈើអីចឹង តើអ្នកបានជួបបទពិសោធន៍អ្វីខ្លះមុននឹងឡើងទៅដល់ចុងឈើ? សម្រាប់ខ្ញុំ ពេលឡើងដល់ចុងដើមឈើប្រកបបានសម្រេចហើយប្រកបដោយសុវត្ថិភាព ខ្ញុំគិតថាខ្ញុំបានធ្វើកិច្ចការមួយធ្វើឲ្យខ្លួនឯងសប្បាយចិត្តខ្លាំងមែនទែន។ ខ្ញុំយល់ថាខ្លួនឯងចេះជម្នះភាពភ័យខ្លាច ដែលជាមេរៀនមួយសម្រាប់ទទួល និងស្វែងរកបទពិសោធន៍ ក៏ដូចជាការយល់ឃើញអ្វីមួយដោយខ្លួនឯង ហើយប្រៀបធៀបនឹងអ្វីដែលគេបាននិយាយប្រាប់ពីមុនមក តើវាខុសគ្នាកម្រិតណា។

ចំណុចតូចៗទាំងនេះ បានជំរុញចិត្តខ្ញុំនិងក្រុមការងារចាប់ដៃគ្នាចងក្រង « Outdoor » Issue នេះឡើង ដោយប្រើមួយខែពេញដើម្បីបញ្ចប់បេសកកម្មនៅលេខនេះ។

មិត្តអ្នកអាននឹងបានឃើញពីសកម្មភាព Outdoor ថ្មីៗមួយចំនួនៗដែលក្រុមការងារ Sabay Magz ព្យាយាមប្រមូលព័ត៌មាន និងផ្តិតយកសកម្មភាពទាំងនោះមកបញ្ចូលគ្នា ដើម្បីផ្តល់បទពិសោធន៍ថ្មីមួយ ជុំវិញសកម្មភាពកម្សាន្ត Outdoor របស់អ្នកទាំងអស់គ្នា។ ខ្ញុំ និងក្រុមការងារ Sabay Magz នឹងខិតខំស្វែងរកអ្វីដែលថ្មីមកបង្ហាញមិត្តអ្នកអានទាំងអស់គ្នាជាបន្តទៀតនៅខែក្រោយ។

អរគុណដែលតែងតែគាំទ្រ Sabay Magz តាំងពីដើមរហូតមកទល់ពេលនេះ។ កុំភ្លេចណា! ជួបគ្នាខែក្រោយ ដែលយើងនឹងនិយាយពី « GEEK » Issue។

ដោយក្តីគោរពពីខ្ញុំ
គុង

ប្រធានផ្នែកគ្រប់គ្រង I EDITOR: **លុក វណ្ណារ៉ង** LUOK VANNRONG
ផ្នែករៀបចំ និង រចនា I GRAPHIC: **សឹក សំលា** SOEK SELA (JOONSUE)
អ្នកសម្របសម្រួល I COORDINATOR: **លី សុផាត** LY SOPHAT
ផ្នែកថតរូប I PHOTOGRAPHERS: PU SEM, Mr. LEE.
ផ្នែកព័ត៌មាន I REPORTER : **ចាន់ សុនិតា** CHAN SONITA

អាសយដ្ឋាន អគារ ៣០៨ មហាវិថីព្រះមុនីវង្ស រាជធានី ភ្នំពេញ បោះពុម្ពផ្សាយ៖ ប្រទេសកម្ពុជា,
រោងពុម្ព៖ ព្រីន ម៉ាស្ទ័រ ទំនាក់ទំនងការិយាល័យ PHONE: (855) 023 228 000 /FAX: (855) 23 218 588
អ៊ីមែល៖ INFO@CIDC.COM.KH /WWW.SABAY.COM

Smart ដូរលុយ ទ្បើយជាងគេ!

- ស្មើនឹងអ៊ីនធឺណិត 1,000 MB
- សុពលភាព 12 ថ្ងៃ
- ក្រុមហ៊ុនទូរស័ព្ទតែមួយគត់ ដែលផ្តល់សេវា 4G LTE ទូទាំង 25 ខេត្តក្រុងនៅកម្ពុជា

ទទួលបានកាន់តែច្រើនជាមួយ
Smart ដូរលុយ ថ្មី

លុយ	ដូរបាន	សុពលភាព	របៀបដូរលុយ
10 សេន	1 ដុល្លារ	1 ថ្ងៃ	*656*10#
20 សេន	3 ដុល្លារ	2 ថ្ងៃ	*656*20#
50 សេន	8 ដុល្លារ	7 ថ្ងៃ	*656*50#
1 ដុល្លារ	20 ដុល្លារ	12 ថ្ងៃ	*656*100#
2 ដុល្លារ	40 ដុល្លារ	25 ថ្ងៃ	*656*200#

ព័ត៌មានបន្ថែម: 888 ឬ 010 200 888
SmartAxiata SmartAxiataOfficial
Smart
smart.com.kh
an axiata company

VOX POP

IF U HAD 2,000$. WHERE WOULD U GO FOR TRIP IN CAMBODIA

Voleak

និយាយទៅខ្ញុំចូលចិត្តទៅលេងមាត់សមុទ្រ ហើយបើមានលុយ$2000គឺដឹងតែទៅលេងកំពង់សោម តែម្តងជាមួយគ្រួសារទាំងអស់គ្នា ហើយបើអាចឈាងទៅលេងកោះ ក្បែរៗនោះថែមទៀត។ ព្រោះខ្ញុំចង់ញ៉ាំបាយជុំគ្នាជាមួយអ្នកផ្ទះនៅមាត់ឆ្នេរ និងលេងទឹកសមុទ្រហើយអាចលេងបាញ់កាំជ្រួចពេលយប់ទៀតគ្រាន់តែស្រមៃក៏សប្បាយចិត្តដែរ។

Rithy

ក្តីស្រមៃរបស់ខ្ញុំគឺ នាំប៉ាម៉ាក់របស់ខ្ញុំទៅលេងខេត្តមណ្ឌលគិរី ទាំងអស់គ្នា ព្រោះអី មិនធ្លាប់បានទៅលេងនៅទីនោះសូម្បីតែម្តង ធ្លាប់តែមើលតាមទូរទស្សន៍ ហើយលឺគេថាសប្បាយ ទើបគិតថាបើមានឱកាសចង់ទៅដើរលេងមើលទេសភាពព្រៃភ្នំជាមួយប៉ាម៉ាកម្តងនិងបានស្រូបយកខ្យល់អាកាសបរិសុទ្ធពីធម្មជាតិផងដែរ។

Thyda

បើមានលុយ$2000សម្រាប់ដើរលេងមែន ខ្ញុំនឹងទៅលេងកោះរុងជាមួយគ្រួសាររបស់ខ្ញុំតាម!! ព្រោះនៅទីនោះមានទេសភាពស្រស់ស្អាត ហើយRomantic ហើយខ្សាច់សស្អាតសុម្បីតែទឹកសមុទ្រ ឡើងខៀវថ្លាឆ្លងគូរឲ្យចង់លេង។ ណាមួយវាអាចធ្វើឲ្យខ្ញុំមានអារម្មណ៍ថា ធូរស្រាលពីស្ត្រេស និងភាពមមាញឹកដែលមានផងដែរ។



Marya

បើខ្ញុំវិញមានលុយប៉ុនហ្នឹងវិញកន្លែងដែលខ្ញុំនឹកឃើញចង់ទៅមុនគេនោះគឺខេត្តមណ្ឌលគិរីហើយចង់ទៅជាមួយម៉ាក ព្រោះគិតចង់ទៅលេងយូរហើយតែមិនមានឱកាសល្អសោះ ខ្ញុំចូលចិត្តទឹកជ្រោះ ហើយដើរលេងព្រៃព្រឹក្សានិងញ៉ាំបាយនៅតំបន់ធម្មជាតិវាពិតជាមានអារម្មណ៍ថា សប្បាយរីករាយ ជាពិសេសនោះ គឺអាចទៅលេងភូមិសហគមន៍ជនជាតិថែមទៀត។

THIS IS A BURGER.

FAT BOYS
THE BURGER BAR

WE ARE LOCATED
#16 street 57
Sangkat Boeng Keng Kong 1
Phnom Penh

Contact : 092 188 188 - 023 985 368

២យប់៣ថ្ងៃដើរលេងឲ្យសព្វកន្លែងនៅមណ្ឌលគិរី

ពេលធុញថប់ធ្លាប់គិតទេថាទៅណាឲ្យសប្បាយ ហើយប្លែកអារម្មណ៍? មានតែធម្មជាតិទេដែលតែងតែធ្វើឲ្យយើងមានអារម្មណ៍ធូរស្រាលមិនចេះធុញទ្រាន់ ដូច្នេះ Sabay Magz សូមនាំអ្នកឲ្យបានដឹងពីអាថ៌កំបាំងនៃធម្មជាតិដែលលាក់ខ្លួននៅក្នុងខេត្តមណ្ឌលគិរី។

ចង់ដើរលេងឲ្យសព្វកន្លែងកម្សាន្តទាំងអស់ នៅក្នុងខេត្តមណ្ឌលគិរី អ្នកអាចចំណាយត្រឹមតែ ២យប់៣ថ្ងៃ ហើយចំណាយអស់ថវិកាសមរម្យប៉ុណ្ណោះ ដើម្បីស្គាល់នូវកន្លែងធម្មជាតិ និងស្វែងរកបទពិសោធន៍ថ្មីក្នុងដំណើរកម្សាន្តរបស់អ្នក។

តាមរយៈលោក ចិន្តា ដែលជាអ្នករៀបចំដំណើរកម្សាន្តនៅក្នុងខេត្តមណ្ឌលគិរីផ្ទាល់ បានប្រាប់Sabay Magz ថាអ្នកទេសចរណាក៏ដោយឲ្យតែបានមកលេងនៅទីនេះរួចហើយ តែងត្រឡប់ទៅវិញជាមួយភាពស្រស់ស្រាយ និងអនុស្សាវរីយ៍ដែលចងចាំមិនភ្លេច។ ដំណើរកម្សាន្តនៅមណ្ឌលគិរីនេះមាន២បែបគឺ ដំណើរកម្សាន្តគ្រប់ទីកន្លែងធម្មជាតិធម្មតា និង ដំណើរកម្សាន្តចូលក្នុងព្រៃបែបផ្សងព្រេង ដែលភ្ញៀវខ្មែរភាគច្រើនចូលចិត្តដើរលេងកន្លែងធម្មជាតិធម្មតា ឯភ្ញៀវបរទេសភាគច្រើនចូលចិត្តដើរលេងលក្ខណៈផ្សងព្រេងជាងភ្ញៀវក្នុងស្រុក។

ដំណើរកម្សាន្តទៅកន្លែងធម្មជាតិធម្មតា

ទីកន្លែងសំខាន់ជាងគេដែលគេមិនអាចរំលងបាន នោះគឺជ្រោះប៊ូស្រា ដែលជាទីកជ្រោះដ៏ល្បីល្បាញមួយរបស់ខ្មែរយើង បន្ទាប់មកមានការទៅលេងនៅភូមិតាំង ចម្ការកាហ្វេនិងប៊ឺរ ក៏ដូចជាភ្នំដោះក្រមុំ និងមើលទេសភាពព្រៃភ្នំពីរមណីយដ្ឋានសមុទ្រឈើ ហើយទៅលេងទីកធ្លាក់សែនមនោរម្យថែមទៀត។ អ្នកត្រូវចំណាយប្រហែលជា $៦០ ក្នុង១ថ្ងៃ ដើម្បីជួលឡានទៅលេងគ្រប់ទីកន្លែងខាងលើ រួមមានទាំងអ្នកនាំផ្លូវម្នាក់ទៅជាមួយ។

ដំណើរកម្សាន្តចូលព្រៃបែបផ្សងព្រេង

អ្នកអាចដើរលេងគ្រប់ទីកន្លែងដូចខាងលើដែរ តែអ្វីដែលពិសេសបន្ថែមនោះគឺ មានការដើរចូលក្នុងព្រៃហើយទៅលេងដល់សហគមន៍ជនជាតិព្នង ដែលការដើរត្រូវចំណាយពេលប្រហែល៥ម៉ោង ជាមួយនឹងធម្មជាតិ អ្នកអាចជិះដំរី និងក្បួនលេងទៀតផង។ ដល់ទីកន្លែងដែលឈប់សម្រាកគឺមានការបោះតង់ ឬចងអង្រឹងគេងនៅក្នុងព្រៃ។ នៅក្នុងដំណើរកម្សាន្តនេះអ្នកចំណាយត្រឹមតែ$៣០ក្នុងម្នាក់ ដែលក្នុងនោះមានអ្នកនាំផ្លូវ និងអ្នកចាំចម្អិនម្ហូបឲ្យញ៉ាំទៀតដោយគ្មានការព្រួយបារម្ភ។

គិតហើយឬនៅ អីចឹងចាចង់ទៅដើរលេងនៅកន្លែងណាបែបធម្មជាតិលើកក្រោយនេះ? សាកទៅធ្វើដំណើរផ្សងព្រេងនៅមណ្ឌលគិរីទាំងអស់គ្នាម្តងមើល៍! ព័ត៌មានបន្ថែមពីការធ្វើដំណើរនៅខេត្តមួយនេះ មិត្តទាំងអស់គ្នាអាចទាក់ទងទៅលោក ចិន្តា ដែលអ្នករៀបចំ Tour កម្សាន្ត ទូរសព្ទលេខ 0966900505 /099900505 /092900505 / 0889744489 ឬចូលទៅកាន់ទំព័រ http://www.mondulkiriadventuretour.com/។

និតា

ប្តូរពីជិះទ្បានដើរលេង មកជិះម៉ូតូកាត់ភក់ម្តងមើល



ពេលខ្លះវាដូចជាដដែលៗពេកដែលទៅដើរលេងជិះតែទ្បាន ជួនកាលគេងលក់ក្នុងទ្បានបាត់ អត់បានមើលទេសភាពតាមផ្លូវក៏មានឥឡូវនេះមានសេវាកម្មនាំយកទៅធ្វើដំណើរផ្សងព្រេងដោយជិះម៉ូតូចូលព្រៃ កាត់កូមិស្រុកដែលធ្វើឲ្យយើងទទួលបានដំណើរកម្សាន្តបែបសប្បាយថ្មីៗ Dancing Road Dirt Bike Tour ចាប់ផ្តើមបើកតាំងពីឆ្នាំ២០០០មកម្ល៉េះ ក្រោមការសហការដៃគូរវាងខ្មែរ និងអង់គ្លេស និងបានបង្កើតដំណើរកម្សាន្តជិះម៉ូតូផ្សងព្រេងជាលក្ខណៈក្រុម ទៅតាមខេត្តនានាជាច្រើនរាប់មិនអស់រួចមកហើយ ។

ក្នុងការធ្វើដំណើរតាមម៉ូតូនេះ គឺអ្នកអាចមានជម្រើសច្រើនដូចជាទៅខេត្តមណ្ឌលគិរី រតនគិរី សៀមរាប កោះកុង ឬតាមតំបន់ភ្នំ និងតំបន់ប្រាសាទផ្សេងៗជាច្រើនកន្លែងទៀត ដែលក្នុងម្នាក់ចំណាយប្រហែល $១០៥ សម្រាប់ដំណើរកម្សាន្តក្នុងមួយថ្ងៃដែលមានរួមបញ្ចូលទាំងម៉ូតូ សាំង សំលៀកបំពាក់សម្រាប់ការពារពេលជិះម៉ូតូ និងការហុបចុកតាមផ្លូវ ហើយមានអ្នកចាំនាំផ្លូវផងដែរ។ នៅមានដំណើរកម្សាន្តច្រើនយប់ ច្រើនថ្ងៃទៀតដោយអ្នកអាចសម្រេចចិត្តទៅកន្លែងដែលមាននៅក្នុងគម្រោង Tour ដែលមានស្រាប់នៅក្នុងគេហទំព័រ www.dancingroads.com ។

គោលបំណងរបស់Dancing Road Dirt Bike គឺចង់នាំលោកអ្នកទៅកាន់ដំណើរកម្សាន្តបែបផ្សងព្រេងហើយនាំលោកអ្នកឲ្យបានឃើញ និងស្គាល់នូវសម្រស់ធម្មជាតិដែលកប់បាត់នៅក្នុងព្រៃហើយ មិនមែនគ្រប់គ្នាសុទ្ធតែធ្លាប់ឃើញ ក៏ដូចជាការបង្កើនទំនាក់ទំនងសុិទ្ធស្គាល ពេលធ្វើដំណើរួមគ្នា។លោកអ្នកពិតជាមិនបានដឹងថា វាសប្បាយរីករាយ និងរំភើបប៉ុណ្ណាទេ ទាល់តែអ្នកឆ្លៀតរកឱកាសល្អណាមួយហើយសាកល្បងជិះម៉ូតូធំ កាត់ទឹកឡើងភ្នំម្តង ទើបបានដឹងថាប្រទេសយើងមានធនធានធម្មជាតិជាច្រើនដែលរង់ចាំឲ្យមនុស្សចូលទៅស្និទ្ធស្នាលជាមួយ។

ទំនាក់ទំនងសម្រាប់រៀបចំដំណើរកម្សាន្តជាក្រុមរបស់អ្នកតាមរយៈ:
លេខទូរស័ព្ទ:
012 753 008 (Paeng)
012 822 803 (Sonia)
អាសយដ្ឋាន #66c St. 368, Phnom Penh, Cambodia

និតា

WAKEBOARDING

Wakeboarding កីឡាកូនកាត់ថ្មីដំបូងបង្អស់នៅកម្ពុជាដោយសារភាពរីកចម្រើនគ្រប់វិស័យនៅប្រទេសយើងឃើញថាវិស័យកីឡាក៏មានភាពសំបូរបែបដូចគ្នាព្រោះកីឡាថ្មីៗជាច្រើនចាប់ផ្តើមមានវត្តមាន ដោយកីឡាខ្លះគឺយើងពុំដែល បានស្គាល់ទាល់តែសោះ។ ថ្ងៃនេះSabayនឹងនាំអ្នកឲ្យបានស្គាល់នូវកីឡាថ្មីមួយហៅថា Wakeboarding ដែលជាកីឡាថ្មីដំបូងបង្អស់នូវកម្ពុជាដែលមាននៅ Kam Air Wakepark តែមួយគត់។

Wakeboarding ជាកីឡាកូនកាត់ដែលបានមកពីការបូកបញ្ចូលគ្នានូវកីឡាស្គីបន្លះទឹកកកនិងកីឡាស្គីលើទឹកចូលគ្នាតែមួយ ដោយការលេង Wakeboarding នោះគឺគ្រាន់តែឈរលើបន្លះក្តារស្គីនៅលើទឹកហើយនឹងម៉ាស៊ីនសម្រាប់អូសស្គីពេលកំពុងជិះ។ពេលនោះអ្នកអាចបង្ហោះខ្លួនទៅលើអាកាស រីឯជុំគ្រប់ស្តាយដែលអ្នកចង់ពេលដែលម៉ាស៊ីនអូសអ្នកនៅលើទឹក វាជា ឱកាសដ៏ល្អសំរាប់អ្នកដែលចូលចិត្តស្វែងរកអ្វីដែលថ្មីៗនិងលេងកម្សាន្ត។ ដើម្បីការលេង Wakeboardingដ៏សប្បាយរីករាយនេះអ្នកចំណាយត្រឹមតែ$២០ក្នុងរយៈពេល១ម៉ោង សម្រាប់ការលេងហើយទទួលបាននូវបទពិសោធន៍កីឡាថ្មីដ៏អស្ចារ្យមួយនេះជាមួយ Kam Air Wakepark ។

Kam Air Wakepark មានទីតាំងឆ្លងពីបឹងទន្លេសាបជិតស្ពានព្រែកព្នៅដែលអមទៅដោយដើមត្នោត៨៧ដើមដ៏ស្រស់ស្អាត។ សម្រាប់ពត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័ររបស់ Kam Air Wakepark

ជិះឡានកង់ធំៗ ចូលព្រៃលេងជាមួយ 4WD ADVENTURE

ដូចជាប្លែកបន្តិចបើនិយាយពីរឿងជិះឡានកង់ធំៗចូលទៅព្រៃជ្រៅ តែនេះជាបទពិសោធន៍ថ្មីមួយ សម្រាប់ប្រិយមិត្តដែលចូលចិត្តបង្កើតសកម្មភាព Outdoor ប្លែកៗ ពីការដើរលេងកម្សាន្តៗ អ្នកនឹងបានបទពិសោធន៍អ្វីខ្លះពីការចូលរួមជាមួយ 4WD Cambodia Adventure ?

លោកព្រំ រស្មី ជាអ្នកបង្កើតក្លឹបនេះឡើង បានប្រាប់ពីគោលបំណងនៃការបង្កើត Club នេះថា លោកមិនមានគោលបំណងអីធំដុំនោះទេ អ្វីដែលធ្វើឡើងនេះគឺគ្រាន់តែចង់ប្រមូលនិងបង្កើនមិត្តភាព ក្រុមអ្នកចូលចិត្តបើកឡានប្រភេទកង់ធំៗនេះ មកជួបជុំគ្នាដើម្បីស្វែងរកបទពិសោធន៍ថ្មី តាមរយៈការរុករកសម្រស់ធម្មជាតិដ៏ស្រស់បំព្រងនៅប្រទេសខ្មែរយើង។

លោកបន្តថា សកម្មភាពដែលក្រុម 4WD Cambodia Adventure ធ្លាប់បានឆ្លងកាត់កន្លងមក មានដូចជា ការជិះឡានកាត់តក់ កាត់ទឹក កាត់ដងអូរ និងឡើងភ្នំជាដើម។ បើកបរលើផ្លូវពិបាកៗ ប្រាកដជាមានឧបសគ្គច្រើនហើយ តែវានឹងផ្តល់កម្លាំងចិត្តដ៏អស្ចារ្យមួយ ពេលដែលយើងសម្រេចការងារមួយគ្នាហើយឆ្ពោះដល់គោលដៅដែលបានកំណត់នោះ។

ដំណើរកម្សាន្តមួយនេះមានលក្ខណៈខុសគ្នាពីការជិះឡានដើរលេងនៅតាមខេត្តដែលយើងធ្លាប់ទៅ ព្រោះវាមានភាពលំបាកដោយជិះចូលទៅក្នុងព្រៃ ឬឡើងភ្នំរុករកកន្លែងដែលស្អាតៗ ហើយញ៉ាំបាយជុំគ្នា ប្រៀបដូចជាដំណើរផ្សងព្រេងដ៏អស្ចារ្យមួយ។

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៥ នេះនឹងមានកម្មវិធីធ្វើដំណើរផ្សងព្រេងទៅតំបន់អារ៉ែង រយៈពេល២យប់៣ថ្ងៃ ដែលមានការឧបត្ថម្ភពីTop One Oil ដូច្នេះសម្រាប់អ្នកដែលមានចំណាប់អារម្មណ៍ចង់ធ្វើដំណើរផ្សងព្រេងនេះ អាចទៅចុះឈ្មោះចូលរួមនៅក្លឹប 4WD Cambodia Adventure ចាប់ពីពេលនេះតទៅដោយមានឡានផ្ទាល់ខ្លួន ឬអាចជិះជាមួយអ្នកដទៃបាន។

ថ្លៃចុះឈ្មោះ តម្លៃ $២០ សម្រាប់មនុស្ស៣ទៅ៨នាក់រួមដំណើរជាមួយ ក្នុងតម្លៃនេះគឺរួមបញ្ចូលទាំងអាហារថ្ងៃត្រង់និងពេលយប់សម្រាប់អ្នកដែលចូលរួមទាំងអស់ ហើយអ្នកនឹងទទួលបានការប្តូរប្រេងម៉ាស៊ុនឡានពី Top One Oil និងលាងរថយន្តFree នៅយានដ្ឋានពេញចិត្ត។

និតា

QR Scan
to play VIDEOs

Kite Surfing Board

ចូលចិត្តលេងកីឡាដែលរំភើបរីករាយ លើផ្ទៃសមុទ្រដែរឬទេ ? នេះគឺជាកីឡាកម្សាន្តដ៏រីករាយប្លែកអារម្មណ៍ដែលអ្នកអាចបណ្តែតខ្លួនទៅលើអាកាសនិងផ្ទៃទឹកសមុទ្របានតាមជំនោរខ្យល់សមុទ្រកម្ពុជា។

កុំបារម្ភថាពិបាកជិះ! បើសិនជាអ្នកចង់សាកល្បងកីឡាប្រភេទនេះ អ្នកនឹងត្រូវបានជំនាញជាច្រើននាក់ចាំជួយបង្រៀនអ្នកឲ្យចេះលេងកីឡា Kite Boarding បានយ៉ាងសប្បាយរីករាយ។ ក្រៅពីការបង្ហាត់បង្រៀនតាមបទពិសោធន៍ និងជំនាញផ្ទាល់ពីអ្នកជំនាញ កីឡា Kite Boarding មួយនេះ ក៏មានការធានាពីអង្គការ Kite Board អន្តរជាតិផងដែរ ដែលធានាចំពោះការលេងឲ្យមានភាពត្រឹមត្រូវនិងសុវត្ថិភាព ។



លោក Frank Van Zoggel ជាអ្នកគ្រប់គ្រង និងជាអ្នកឯកទេសជំនាញក្នុងការបង្រៀនលេងកីឡានេះ បានប្រាប់ Sabay Magz ថា សម្រាប់អ្នកមិនធ្លាប់លេង ក្រុមការងារនឹងបង្ហាត់បង្រៀនជាមុនសិន ដើម្បីប្រាកដថាការកម្សាន្តរបស់ភ្ញៀវទាំងអស់លេងបានតាមបែបស្តង់ដារអន្តរជាតិ និងមានសុវត្ថិភាពខ្ពស់។

លោកបន្តថា ការបង្ហាត់មានជាដំណាក់កាល ប៉ុន្តែមិនប្រើពេលយូរទេ ព្រោះទ្រឹស្តីនិងការអនុវត្តដើរស្របគ្នា និយាយរួមគឺធ្វើយ៉ាងណាឲ្យអ្នកលេងកម្សាន្តមានអារម្មណ៍រីករាយ ហើយមានសុវត្ថិភាព។

Kite Boarding នេះគឺស្ថិតនៅតំបន់កែបថ្មី។ ប្រធានគ្រប់គ្រងកីឡា Kite Board នេះបន្ថែមថា មូលហេតុដែលក្រុមការងារជ្រើសយកទីតាំងនៅកែប ព្រោះ ទឹកសមុទ្រនៅទីឆ្នេរកែប មានទឹកលតហើយទឹកសមុទ្រមិនសូវជ្រៅ ដូច្នេះអ្នករលងមិនសូវបារម្ភច្រើននោះទេ។ ចំពោះរដូវកាលលេងវិញ គឺលេងបានស្ទើរគ្រប់ពេល តែពេលដែលមានខ្យល់ល្អបំផុតធ្វើឲ្យការលេង Kite Boarding បានកាន់តែសប្បាយនោះគឺស្ថិតនៅកំឡុងខែភ្ជៀងរហូតដល់បំណាច់ខែ តុលា។

Photos provided by Cambodia Kite Boarding

Exciting Feelings, Kiteboarding Kampot, Cambodia.

សម្រាប់អ្នកដែលមានការចាប់អារម្មណ៍នឹងល្បែងប្រភេទនេះ អាចមានឱកាសទៅលេងបានហើយនៅខេត្តកែប ដែលលោកអ្នកអាចទំនាក់ទំនងបានតាមរយៈទូរស័ព្ទលេខ៖ ០៨៩ ២៩០ ៧១៨ / ០១៧ ២៩១ ៧៨២ ឬ ចូលទៅកាន់គេហទំព័រFacebook របស់ Cambodia Kite Boarding ។

Kite Boarding Rate:
Beginner Course for kite boarding $290 About 8Hours
$35 Per Lesson for 1Hour
$30 Per Rent for 1Hour

សួនមេអំបៅ
ដ៏ស្រស់បំព្រងនៅខេត្តកែប





MODEL: សាឡាត់ ស្រីឡាង
PHOTO: Mr. Lee

នឹកដល់ខេត្តកែប មិត្តអ្នកអានប្រហែលជានឹកឃើញដល់ឆ្នេរកែប
ឬក៏កោះទន្សាយហើយ។ តែអ្វីដែល Sabay Magz
លើកមកនិយាយនៅពេលនេះ គឺមិនមែនឆ្នេរ ឬក៏កោះឡើយ
គឺជាសួនមេអំបៅដ៏អាថ៌កំបាំងមួយក្នុងខេត្តមួយនេះ។

ក្រឡេកមើលតាមផែនទីដែលបានបង្ហាញ សួនមេអំបៅមួយនេះ
គឺស្ថិតនៅមិនឆ្ងាយពីទីប្រជុំជនប៉ុន្មានទេ។
តែអ្នកដំណើរត្រូវចំណាយពេលបន្តិចដើម្បីធ្វើដំណើរទៅបង្កេះភ្នំមួយក្រោយ
ផ្លូវវិមានឯករាជ្យខេត្តកែប។

តាមដងផ្លូវទៅកាន់សួនធម្មជាតិមួយនេះ
អ្នកដំណើរនឹងបានឃើញផ្កាចម្រុះពណ៌ អមទៅដោយភ្លៀនក្រអូបប្រហើរ
ផ្តល់ភាពទាក់ទាញឲ្យមេអំបៅដែលម្ចាស់សួនមួយនេះ បានបង្កាត់ទាំងអស់
ហោះចេញមកបង្ហូតសម្រស់ដល់អ្នកទេសចណ៍។
បន្ថែមពីភាពទាក់ទាញពីការទស្សនាមេអំបៅ
អ្នកដំណើរក៏អាចរកកន្លែងអង្គុយលេង
ស្រូបយកខ្យល់អាកាសនៅទីនោះបានដែរ
ព្រោះគេបានរៀបចំកន្លែងជាច្រើនដល់ភ្ញៀវចូលទស្សនា។

កាលចូលកម្សាន្តមិនគិតថ្លៃអីនោះទេ
តែគេមានដាក់ប្រអប់ផ្តល់វិភាគទានគាំទ្រមួយ ដើម្បីចែករំលែក
និងគាំទ្រកម្រៃដល់បុគ្គលិកដែលខំថែរក្សាសួននេះ។

ស្វែងរកព័ត៌មានបន្ថែមពីសួនមួយនេះតាមរយៈអាស័យដ្ឋាន
Email: infor@kepbutterflyfarm.com ឬក៏លេងទូរសព្ទ ៖ Abe 012786986
ឬ 0973660404។

លំហែរអារម្មណ៍ជាមួយការម៉ាស្សារបែបខ្មែរបុរាណ

Angkor Spa មានបទពិសោធន៍ជាង៣ឆ្នាំមកហើយខាងបម្រើសេវាកម្ម Spa ម៉ាស្សានិងមានសេវាកម្មផ្សេងៗទៀតជាង៥០ប្រភេទ ក៏ដូចជាមាននាំចូលនូវផលិតផលថែរក្សាស្បែក មកពីប្រទេសថៃ អង់គ្លេស និងអាមេរិកជាច្រើនមុខដែលធានាចំពោះគុណភាពល្អ សម្រាប់លោកអ្នក។



នៅទីនេះមានបន្ទប់ម៉ាស្សា Spa ជាលក្ខណៈឯកជនចំនួន៥បន្ទប់ និងផ្ទុកមនុស្សបានប្រមាណ៣០នាក់ ដោយសារតែសេវាកម្មល្អឥតខ្ចោះ យើងទទួលបានការគាំទ្រជាខ្លាំងទាំងភ្ញៀវខ្មែរ និងបរទេស។ ដើម្បីទទួលបានអារម្មណ៍ធូរស្រាលពីភាពតានតឹង រីមិនស្រួលខ្លួនលោកអ្នកអាចមកធ្វើការសោកល្បងទទួលការបម្រើសេវាកម្មល្អៗជាច្រើននៅ Angkor Spa.ដែលធានាថាអ្នកនឹងត្រលប់មកលើកក្រោយម្តងទៀត។

លោកអ្នកអាចទំនាក់ទំនងអង្គស្ប៉ា តាមរយៈ
អាសយដ្ឋាន:
ផ្ទះលេខ១៦ ផ្លូវ៣១០សង្កាត់ បឹងកេងកង១
ខាន់ចម្ការម៉ន
ឬលេខទូរសព្ទ ០២៣ ៥៥៥ ៦១៦៨

NEW CLEAR SAKURA FRESH

ក្រុមហ៊ុន Unilever បានធ្វើការណែនាំផលិតផល ក្លៀរថ្មី (New Clear Sakura Fresh) ដែលចម្រាញ់ចេញពីផ្កាសាគូរ៉ាស្រស់ និង ណូទ្រាមធិនដែលជួយកម្ចាត់អង្គែ ធ្វើឲ្យស្បែកមានភ្លឺក្រអូបដូចផ្កាសាគូរ៉ាស្រស់។ ការបង្ហាញខ្លួនរបស់ Clear Sakura Fresh បានដង្ហែក្បួនដ៏ធំមួយនៅតាមទីតាំងចំនួន ១៣ សំខាន់ៗ ក្នុងរាជធានីភ្នំពេញ ។ ខាងក្រោមនេះជាសកម្មភាពដង្ហែក្បួនផលិតផល ក្លៀរថ្មី (New Clear Sakura Fresh)៖

RELAXATION
MOOD ON WITH
KHMER TADITIONAL MASSAGE



SAILING

On a limited basis, the Sailing Club offers sailing programs for both beginner and intermediate sailors.

ថ្ងៃបាំងឆត្រជាសណ្ឋាគារ និង Resort ដែលមានបម្រើជូន នូវសេវាកម្មជាច្រើន នៅទីនោះលោកអ្នកអាចស្រូបយកខ្យល់ធម្មជាតិនៅតំបន់មាត់សមុទ្រ និងទទួលទានអាហារគ្រឿងសមុទ្រស្រស់ៗ នៅមុខឆ្នេរសមុទ្រតែម្តង។ អ្វីដែលប្លែកអារម្មណ៍នោះ គឺអ្នកអាចជិះទូកក្តោងលក្ខណៈ Romantic តែ២ នាក់ ឬជាលក្ខណៈគ្រួសារ នៅលើផ្ទៃសមុទ្រដ៏ធំល្វឹងល្វើយ ឬ ចែវទូកកាយ៉ាកនៅលើសមុទ្រមើលព្រះអាទិត្យលិច បានយ៉ាងសប្បាយរីករាយ។

ថ្ងៃបាំងឆត្រ Resort ប៉ប៉ាកាយ Romantic

ថ្ងៃបាំងឆត្រជាសណ្ឋាគារ និងResort ដែលមានបម្រើជូននូវសេវាកម្ម ជាច្រើន នៅទីនោះលោកអ្នកអាច ស្រូបយកខ្យល់ធម្មជាតិ នៅតំបន់មាត់សមុទ្រ និងទទួលទាន អាហារគ្រឿងសមុទ្រស្រស់ៗនៅមុខឆ្នេរសមុទ្រ តែម្តង។ អ្វីដែលប្លែកអារម្មណ៍នោះគឺអ្នកអាចជិះទូកក្តោងលក្ខណៈ Romantic តែ២ នាក់ ឬជាលក្ខណៈគ្រួសារនៅលើផ្ទៃសមុទ្រដ៏ធំល្វឹងល្វើយ ឬ ចែវទូកកាយ៉ាកនៅលើសមុទ្រមើលព្រះអាទិត្យលិចបាន យ៉ាងសប្បាយរីករាយ។

នៅទីនោះក៏មានកន្លែង ដែលអាចញ៉ាំស្រាក្រឡុក ស្តាប់ភ្លេងបណ្តែតអារម្មណ៍ដែលនាំឲ្យអារម្មណ៍រសាយពីទុក្ខបានមួយគ្រាផងដែរ ។ គិតលើបរិយាកាសអំណោយទានពីធម្មជាតិ និងសេវាកម្មរបស់ថ្ងៃបាំងឆត្រ Sabay Magz ជឿជាក់ថាមិត្តទាំងអស់គ្នា នឹងទទួលបានភាពស្រស់ស្រាយក្នុងអារម្មណ៍ ហើយបំបាត់ទុក្ខកង្វល់ ទាំងឡាយដែលបានស្តាយមកពីផ្ទះ និងបង្កើនភាពស្និទ្ធស្នាលក្នុងក្រុមគ្រួសារដែលមិនអាចបំភ្លេចបាននៅ ថ្ងៃបាំងឆត្រ។

Sailing and Kayak Price:

Sailing Boat Rate
Sailing Boat 13feet 1Hr $15
Sailing Boat 13feet 1Hr $25
Instructor 1Hr $8
Kayak Boat Rate 1Hr $5

និតា

DOMINANT CHOICE

HONDA

Click 2016 ជម្រើសដ៏ឆ្លាតវៃនៃមនុស្សសម័យថ្មី

លោក ឧត្តម ច័ន្ទជាអ្នកស្រាលាញ់សុខភាពទើបលោកតែងតែឆ្លៀតពេលទៅហាត់ប្រាណជាប្រចាំ ដើម្បីទទួលបានសុខភាពល្អ និងមានរាងកាន់តែសង្ហា ទោះបីលោកមានភាពមមាញឹកខ្លាំងពីការងារ និងការសិក្សាធ្វើអោយលោកមានពេលវេលាតិចតួចដើម្បីទៅហាត់ប្រាណក៏ដោយ។

ឧត្តម ច័ន្ទបានជ្រើសរើសការលេងបាល់ទាត់ដែលជាកីឡាមួយក្នុងចំនោមកីឡាជាច្រើន ហើយដែលជាកីឡាដែលលោកចូលចិត្តបំផុត។លោកនិយាយថា ទោះរវល់ច្រើនមែនតែលោកមិនត្រូចកីឡាទេ លោកតែងតែណាត់ជាមួយមិត្តស្នេរអាល់អាទិត្យ និយាយរួមគឺសន្សំសំចៃពេលវេលាដើម្បីកីឡាដែលខ្លួនស្រលាញ់។

លោកបន្តទៀតថាដោយសារតែលោកជាមនុស្សចូលចិត្តសន្សំសំចៃពេលវេលា ទើបលោកជ្រើសរើសយកម៉ូតូហុងដា Click 2016ជាមធ្យោបាយធ្វើដំនើរ ផ្អែកលើចំណុចសំខាន់2 គឺទី1កាត់បន្ថយការកកស្ទះចរាចរណ៍ធ្វើអោយ លោកបានទៅដល់ទីដៅដែលលោកចង់ទៅបានឆាប់ហ៊ស ទី2ចំនេញពេលហើយចំនេញសាំងទៀតព្រោះហុងដា Click 2016 បានបំពាក់ទៅដោយបច្ចេកវិទ្យា ស៊ីសាំងតិច និងទំនើបលើសពីម៉ូតូផ្សេងៗដែលលោកធ្លាប់បានប្រើប្រាស់។ ហុងដា Click 2016 មានរាងឡូយ សង្ហាតូចល្មមហើយសមនឹងស្ទីល យុវវ័យចូលចិត្តកីឡា និងមានភាពជឿជាក់លើខ្លួនឯង។

HERO4 BLACK

2x the performance, yet again. Simply the best.

លក្ខណៈពិសេសថ្មីជាមួយនឹង GoPro Hero4 Black ដែលថតវីដេអូច្បាស់ជាងមុនទៅទៀត ដល់ទៅ 4k Ultra HD និងមានភាពហ័សរហួនជាងGoPro មុនៗទៀតហើយអាចថតជាប់ Slow Motion បាន240Framesក្នុងរយៈពេល ១វិនាទី។ វាអាចថតបាននូវក្រោមជម្រៅទឹកប្រមាណ40ម និងថតជាប់ដល់ទៅ30Frames ក្នុងមួយវិនាទី ហើយមានកម្មវិធីថ្មីនៅក្នុងនោះគឺ New Setting After Dark វាជួយដល់ការថតរូបនៅពេលយប់ក្នុងទីងងឹតឲ្យមានពន្លឺភ្លឺច្បាស់លើសពីបច្ចេកវិទ្យាមុនៗទៀត។ កាន់តែល្អនោះគឺវាបានបន្ថែមសមត្ថភាពទៅលើ Audio Performance ដែលជួយសម្រួលដល់ការថតវីដេអូមានសំឡេងកាន់តែច្បាស់ ល្អដូចសំឡេងដើមកំពុងថត។

4K30

Professional Video up to 4K30
Ultra high-resolution, high frame rate 4K30, 2.7K50 and 1080p120 video.

2x

2x The Performance
Improved image quality. 2x more powerful processor. 2x faster video frame rates.

12MP

Fast, Powerful Photo Capture
Captures high-quality 12MP photos at speeds up to 30 fps.

Built-in Wi-Fi + Bluetooth
Enhanced connectivity to the GoPro App.

GoPro Be a HERO.

SONY

MUSIC DESERVES RESPECT

"Sony MDR Headphone, my perfect partner for High Resolution Music quality."

Laura Mam
Official Sony MDR Ambassador

- ជាប្រភេទកាសស្តាប់ត្រចៀកគុណភាពខ្ពស់ ជាមួយនឹងបច្ចេកវិទ្យា Hi-Res Audio.
- ខ្សែកាសធ្វើការតភ្ជាប់ទៅនឹងរន្ធសាកថ្មរបស់ប្រភេទ Android Mini USB និង Lightening iPhone ដើម្បីចាប់យកសម្លេងប្រភេទ Analogue ដែលផ្តល់នូវសម្លេងលឺច្បាស់ហាក់បីដូចជាអ្នកកំពុងស្តាប់ការប្រគុំតន្ត្រីផ្ទាល់។
- មានភ្ជាប់ជាមួយនឹងតំណាខ្សែប្រភេទ Mini Jack 3.5mm ផងដែរ។

Hi-Res AUDIO

លោកអ្នកអាចរកជាវបាននៅតាមដំណាងចែកចាយលក់របស់ ក្រុមហ៊ុន SONY
Sony Music Café:
Kfour Group Ltd. Soriya level 3 Sunsimexco Co, Ltd.
Kim Heng Center (No. 118., South of Central Market)
Nojima (Level1, Aeon Mall).

NANO WATER CAN

N A N O T E X H N O L O G Y

Nano Can ជាដបសម្រាប់ដាក់ទឹក ដែលអ្វីដែលអស្ចារ្យនោះគឺពេលដែលចាក់ទឹកចូលទៅវានឹងបំបែកម៉ូលេគុលទឹកធម្មតា ឲ្យស្របទៅនឹងទំហំកោសិការបស់មនុស្សយើងព្រោះការស្រាវជ្រាវបានឲ្យដឹងថាទឹកដែលយើងញ៉ាំ រាល់ថ្ងៃមានម៉ូលេគុលធំជាងកោសិការបស់មនុស្ស ដូច្នេះទឹកដែលញ៉ាំចូលទៅគឺប្រើប្រាស់បានតិចតួចបំផុត។

ជាមួយបច្ចេកវិទ្យាNanoចុងក្រោយរបស់ជប៉ុន Nano Can ត្រូវបានផលិតម្បឿងពីដែកទីតាញ៉ូម កិនលាយនឹងថ្មកំអែភ្នំភ្លើង និងដែកអឺណុកលេខ១ ដែលក្នុងកំអែភ្នំភ្លើងនោះមានផ្ទុកសារជាតិ Far Infrared ដែលអាចធ្វើឲ្យដបមានកម្រិតរំញ័រដល់ទៅ២៥0,000ដងក្នុង១វិនាទី ក្នុងការបំបែកទឹកពេលដែលចាក់ចូលទៅ ហើយវាអាចរក្សាកម្តៅទឹកក្តៅក្នុងដបនោះដល់ទៅ១២ម៉ោង។ ជាពិសេសអាចធ្វើការពិសោធបានភ្លាមៗ ពីប្រសិទ្ធភាពNano Can.ដោយខ្លួនឯងផ្ទាល់។
ប្រភព៖https://smnnanowatercan.wordpress.com/apakah-smn-nano-water-can/



ដោយសារការស្រលាញ់ចូលចិត្តសិល្បៈ និងកីឡាយ៉ាងខ្លាំង តាំងពីតូចឪពុករបស់ខ្ញុំបានទិញ Digital Camera ដំបូងឲ្យ ខ្ញុំពេលខ្ញុំអាយុ ១២ឆ្នាំ ហើយពេលនោះខ្ញុំជាអ្នកថតរូបប្រចាំគ្រួសារ និង មិត្តភក្តិរបស់ខ្ញុំនាពេលដំណើរកំសាន្ត និងកម្មវិធីផ្សេងៗ។ ប៉ុន្មានឆ្នាំក្រោយមកបន្ទាប់ពីបញ្ចប់វិទ្យាល័យ ការថតរូបក្លាយជាអាជីពរបស់ខ្ញុំមួយផ្នែកនៅពេលខ្ញុំកំពុងបន្តការសិក្សានៅមហាវិទ្យាល័យច្បាប់ និង Creative Multimedia ។

រាល់រូបភាពដែលខ្ញុំថតទាំងអស់នោះ គឺសុទ្ធតែមានអារម្មណ៍រំភើបចិត្ត (emotional) គំនិតនិងមានអត្ថន័យដូចជាការតែងសេចក្តីបែបខ្លីមួយ ដែលមានន័យគ្រប់គ្រាន់សំរាប់ការយល់ពីព្រឹត្តិការណ៍នីមួយៗដែលកើតឡើង។ ហើយការថតរូបដែលអាចធ្វើឲ្យអ្នកមើលមានអារម្មណ៍រំភើបចិត្តបានគឺយើងត្រូវប្រើអារម្មណ៍និងគំនិតទាំងស្រុងក្នុងការថតទាំងអស់នោះ។

ការថតរូបឲ្យបានច្រើនគឺជាការងាយ តែការផលិតរូបមួយដែលល្អគឺជារឿងមួយដែលពិបាក។ ការយល់អំពីពន្លឺ ប្លង់ និងគំនិត ជាពិសេសការរងចាំព្រឹត្តិការណ៍ ដែលអាចកើតមានតាមការគ្រោងទុកអាចធ្វើឲ្យខ្ញុំផលិតរូបយ៉ាងល្អប្រសើរជាងដែរ។ លើសពីនេះ ដោយសារខ្ញុំមានមូលដ្ឋានគ្រឹះពីកីឡាស្រាប់និងការយល់អំពីចិត្តសាស្ត្ររបស់មនុស្ស ភាពរឿនរហ័ស ការបត់បែនតាមកាលៈទេសៈផ្ទាល់ ធ្វើអោយខ្ញុំអាចផលិតរូបបានកាន់តែល្អប្រសើរជាងការនៅមួយកន្លែងរង់ចាំព្រឹត្តិការណ៍មកដល់។

លោកអ្នកអាចចូលមើលរូបភាពបន្ថែមទៀតនៅក្នុង
www.facebook.com/monsieur.roth

CAPTURE WITH EMOTION

ខ្ញុំឈ្មោះ គីម បញ្ញារ័តន៍ (nickname/ photography name: Monssieur Roth)
អាយុ ២៥ឆ្នាំ។ ជាអ្នកថតរូបសិល្បៈ: ទេសចរណ៍ ដំណើរកំសាន្ត កីឡា កម្មវិធីផ្សេងៗ និង ជីវិតប្រចាំថ្ងៃ។ ៥ឆ្នាំចុងក្រោយ ដោយសារតម្រូវការច្រើនពីក្រុមហ៊ុនទេសចរណ៍ និងតាមស្ថារប័នផ្សេងៗ ការថតរូបទាំងអស់នេះក្លាយជាអាជីពរបស់ខ្ញុំ។

MONSSIEUR ROTH FOTO
+855 78 865 552
+855 15 926 552

PLATINUM
cineplex
THE BEST MOVIES FOR THIS MONTH
GRAP YOUR TICKET
ENJOY THE SHOW

04 AUG 2015

13 AUG 2015



20 AUG 2015

25 AUG 2015

27 AUG 2015

SEARCH PLATINUM CINEPLEX

Google play | App Store

081/086-666-210

More info. www.platinumcineplex.com.kh

SORYA 5 FL.

PlatinumCineplexCambodia | @platinumcineplex | platinumcineplex | PlatinumCineplexCambodia

LOVE ON THE ROCK
28 AUGUST

Jame បានជំពាក់ជីវិតបងប្រុសរបស់គេបន្ទាប់ពីទទួលទោសពីបទឧក្រិដ្ឋដែលពួកគេបានប្រព្រឹត្តរួមគ្នា។ អំឡុងពេល Frankie ជាប់ពន្ធធនាគារ , Jame បានព្យាយាមផ្លាស់ប្តូរជីវិតរបស់គេដោយប្រកបការងារជាក់លាក់មួយស់គ្នាដោយជឿជាក់ថាជីវិតពួកគេនឹងប្រែប្រួលខុសឆ្ងាយពីពេលមុន។

ហើយគាត់ចាប់ផ្តើមមានទំនាក់ទំនងជាមួយមិត្តស្រីចាស់របស់គាត់វិញ។
ពេល Frankieចេញពីគុកមកវិញពួកគេបានចាប់ដៃគ្នាកសាងជីវិតសារជាថ្មីទាំងអស់គ្នាដោយជឿជាក់ថាជីវិតពួកគេនឹងប្រែប្រួលខុសឆ្ងាយពីពេលមុន។

TRAINWRECK
07 AUGUST

SPOOKS
14 AUGUST

VATICANT TAPES
25 AUGUST

LOVE ON THE ROCK
28 AUGUST

តាំងពីតូចមក Amy រស់នៅជាមួយឪពុករបស់នាងដែលជាបុរសមានស្រីច្រើននាងបានក្លាយជាអ្នកសរសេរទស្សនាវដ្តីពេលនាងពេញវ័យក្រោយមកនាងបានប្រើជីវិតរបស់នាងរស់នៅបែបសេរីភាពគ្មានភាពប្រាកដប្រជាហើយមានមិត្តប្រុសពីមួយទៅមួយទៀតដែលនាងមិនបានចាប់អារម្មណ៍ថានាងបានដើរតាមគន្លងឪពុករបស់នាង។ តែមានថ្ងៃមួយដែលនាងបានសរសេរពីអត្ថបទមួយទាក់ទងពីភាពជោគជ័យរបស់គ្រូពេទ្យដែលមានមន្តស្នេហ៍ម្នាក់ពេលនោះនាងចាប់ផ្តើមផ្លាស់ប្តូរការគិតរបស់នាងហើយគិតថាគាត់ខុសពីបុរសមុនៗដែលនាងធ្លាប់ស្គាល់។
ចង់ដឹងទេថាតើលោកគ្រូពេទ្យមានអ្វីទាក់ទាញដល់ Amy រហូតដល់ធ្វើឲ្យមនុស្សម្នាក់ផ្លាស់ប្តូរការរស់នៅរបស់គេ? កុំភ្លេចរង់ចាំតាមដានទាំងអស់គ្នាណ៉ា !

ដោយសារមានភេរវជនរត់គេចពីការយុំយាំងធ្វើឲ្យមានចលាចលដើម្បីដេញចាប់ភេរវជននោះមកវិញមុនពេលចាប់ផ្តើមធ្វើភេរវកម្មទៅលើប្រទេសអង់គ្លេស ដោយក្រុមលោក Will Holloway និងមេបញ្ជាការ Harry Pearce MI5

នេះជាសង្ត្រាមរវាងមនុស្ស និងបិសាច Satan ដែល Angela Holmes នាងទើបតែមានអាយ 27 ឆ្នាំប៉ុណ្ណោះតែនាងមានអំណាចពិសេសម៉ាងដែលនាងអាចធ្វើឲ្យមនុស្សគ្រប់គ្នាដែលនៅជិតនាងអាចមានរបួសខ្លះដល់ស្លាប់ទៀតផង។ ក្រោយមកទើបបានដឹងថានាងមានវិញ្ញាណអាក្រក់សណ្ឋិតហើយព្រលឹងនោះជាបិសាចដែលអាក្រក់ខ្លាំងបំផុតនឹកស្មានមិនដល់។ ពេលនោះសង្ត្រាមដ៏គួរឲ្យភ័យខ្លាចនេះគ្រូវបានចាប់ផ្តើមដែលលោកឪពុក Lozano ជាអ្នកដែលប្រឈមមុខដោះស្រាយមិនមែនដើម្បីតែជួយសង្ត្រោះដល់ Angela នោះទេប៉ុន្តែគឺដើម្បីពិភពលោក។

Fai-Liaw ជាមនុស្សស្រីដែលមានបទពិសោធន៍ក្នុងរឿងស្នេហាច្រើននាងតែងស្រមៃចង់បានទំនាក់ទំនងមួយដែលមានភាពស្រស់ស្រាយមិនតឹងតែងពេកតែក៏ត្រូវមានពេលវេលាគ្រប់គ្រាន់សម្រាប់គ្នាដែរ។ រហូតដល់ពេលដែលនាងបានជួបជាមួយនឹង Bug Joe ដែលជាគូ

ល្អឥតខ្ចោះសម្រាប់នាងព្រោះគេជាមនុស្សល្អស្លូតបូតហើយគេបានបើកហាងធឹកស៊ីមួយដើម្បីតែការជួបជុំស៊ីធឹកសប្បាយរបស់ពួកគេដែលមិនខ្វល់ពីអ្វីផ្សេងច្រើន។ មិត្តភក្តិរបស់គេជាភ្ញៀវប្រចាំហើយពួកគេតែងតែធឹកស្រាជុំគ្នាជារៀងរាល់យប់។

FOLLOW US AT: SABAY MVP

DISTRIBUTED BY sabay/mvp

ផ្លាស់ប្តូរការជិះកង់ទៅជាដំណើរផ្សងព្រេងដ៏រីករាយ

ពេលទំនេរសម្រាកពីការងារ រៀនសូត្រគ្រប់គ្នាតែងមានទម្លាប់ទៅដើរកម្សាន្ត ដើម្បីលំហែខួរក្បាលពីភាពនឿយហត់តាមបែបផ្សេងៗគ្នា តែដោយឡែក លោក ជាតិ បណ្ឌិត និងមិត្តភ័ក្ត ៩ នាក់ទៀត ដែលជាអ្នកចំណង់ចំណូលចិត្តដូចគ្នាតាមរយៈការជិះកង់ដើរលេងជាក្រុម។

ការជិះកង់ជាក្រុមរបស់ លោក បណ្ឌិត មានភាពខុសប្លែកពីការជិះកម្សាន្តធម្មត ត្រង់ថាការជិះកង់រយៈផ្លូវដ៏វែងឆ្ងាយឡើងភ្នំ ចុះព្រៃជាលក្ខណៈផ្សងព្រេងដ៏រីករាយ។ លោកនិយាយថាកត្តាដែលនាំឲ្យពួកលោកជិះកង់ជាក្រុមផ្លូវឆ្ងាយបែបនេះគឺ ដើម្បីចង់ទទួលបានអារម្មណ៍ខុសពីការដើរលេងធម្មតា ដែលជិះឡាន មកពីឆ្ងាយហើយឈប់ញ៉ាំបាយដដែលៗ ឲ្យជាការជិះកង់ជាក្រុមវិញ។

ដំណើរកម្សាន្តដំបូងគេបង្អស់ ដែលក្រុមលោកបានសម្រេចរួមគ្នានោះគឺ ជិះកង់ឡើងគិរីរម្យ។ ការជិះកង់រួមគ្នាមួយនេះ លោកចាត់ទុកថាជាការធ្វើដំណើរប្រកបដោយ សកម្មភាពនិងអនុស្សាវរីយ៍គ្រប់រសជាតិ។ លោកប្រាប់ពីសកម្មភាពទាំងនោះមានដូចជា ជិះកង់មើលទេសភាពលើភ្នំ ការញ៉ាំបាយជុំគ្នា លេងទឹកជ្រោះ បោះតង់គេងលើភ្នំ និងថតរូបលេងជាដើម។

អ្វីដែលធ្វើឲ្យក្រុមលោក កាន់តែសប្បាយរីករាយថែមទៀតនោះគឺការទទួលស្វាគមន៍ពីសហគមន៍ខ្មែរដែលពួកលោកបានជិះកាត់ និងបានចូលរួមជាអំពើសប្បុរសធម៌បន្តិចបន្តួច ដូចជាសៀវភៅ បិច ថ្នាំពេទ្យ និងជួយពន្យល់ប្រជាជនក្នុងភូមិឲ្យដឹងពីការថែរក្សាសុខភាពផងដែរ ព្រោះសមាជិកក្រុមរបស់លោកសុទ្ធតែជាគ្រូពេទ្យ។

មកទល់ពេលនេះគឺមានការជិះកង់លក្ខណៈក្រុមនេះជាលើកទី ៥ រួចមកហើយគឺទៅគិរីរម្យ កោះកុង និងជាយជាត់ ហើយនៅក្នុងការជិះកង់ផ្លូវឆ្ងាយបែបនេះក៏មានផលវិបាកបន្តិចបន្តួចដៃរគើសំខាន់ត្រូវស្គាល់ទីតាំងភូមិសាស្ត្រឲ្យច្បាស ដោយមាន Guide តាមជាមួយ និងជាងធ្វើកង់ព្រោះខ្លាចកង់ខូចតាមផ្លូវ។

លោក បណ្ឌិតបានរំលឹកថា នេះជាបទពិសោធន៍ដំណើរកម្សាន្តដ៏អស្ចារ្យ ដែលជួយបង្កើនភាពស្និតស្នុតក្នុងក្រុម ការចេះជួយគ្នាទៅវិញទៅមក ថែមទាំងបានស្គាល់ពីទីតាំងភូមិសាស្ត្រស្រុកយើងកាន់តែច្បាស់ ហើយទាមទារភាពអំណត់ធ្ងន់ខ្លាំង និងបានចូលរួមចំណែកមនុស្សធម៌ដល់បងប្អូនខ្មែរយើងតាមតំបន់ដាច់ស្រយាលផងដែរ។ សម្រាប់អ្នកដែលមានកង់តែគ្មានក្រុមក៏អាចចូលរួមជាមួយពួកលោកបានដែរព្រោះពួកលោកមានការជិះកង់កម្សាន្តជាក្រុមបែបនេះជារៀងរាល់ឆ្នាំ បើចង់ដឹងថាវាសប្បាយរីករាយអស្ចារ្យប៉ុណ្ណា ក៏ចូលរួមទាំងអស់គ្នាជាមួយគាត់សម្រាប់ដំណើរលើកក្រោយ។ មានចំណាប់អារម្មណ៍ទេ? អាចទាក់ទងទៅលោក បណ្ឌិតបានតាមរយៈទូរស័ព្ទលេខ ៖ 093 801 209

អត្ថបទ៖ និតា

ព្រោះក្តីប្រាថ្នាខ្ពស់ថ្នែម៉ូដមិនខ្លាចហត់

BEAUTIFULLY BIG ASPIRATIONS DESIGNER NOT AFRAID OF FATIGUE

VISAL KOUY

A PASSIONATE YOUNG CAMBODIAN
FASHION DESIGNER

ភាពស៊ីវិល័យចេះតែវិវត្តទៅមុខ ធ្វើឲ្យមនុស្សកាន់តែមានតម្រូវការច្រើនជាងមុនពីមួយថ្ងៃទៅមួយថ្ងៃ ជាពិសេសគឺការស្លៀកពាក់ដែលបង្ហាញអ្នកដទៃឲ្យបានឃើញពីរសនិយម ក៏ដូចជាភាពហ៊ឺហារបស់ខ្លួន។ កត្តានេះបានជំរុញឲ្យ និស្សិតកំលោះវិសាលរៀនថ្នែម៉ូដ ដោយគ្មានភាពរុញរាទោះបីមានសង្គមខាង ក្រៅមួយចំនួនទិតៀនថាខ្លួនជាប្រុសបែរជារៀនធ្វើការងាររបស់មនុស្សស្រី។

«តាមពិតការថ្នែម៉ូដ មិនមែនតម្រូវឲ្យតែមនុស្សស្រីដែលអាចធ្វើបានទេ មនុស្សប្រុសក៏អាចធ្វើវាដែរសំខាន់ភាពវៃឆ្លាតនិងថ្នែប្រឌិត វាទាមទារភាពអំណត់ខ្លាំងមែនទែន» វិសាលប្រាប់មកកាន់Sabay។ ក្នុងនាមជាអ្នកថ្នែម៉ូដសំលៀកបំពាក់ ពិតជាមានភាពតានតឹងខ្លាំងណាស់ពេលខ្លះ ព្រោះត្រូវនឹកគិតពីអ្វីដែលថ្នែប្រឌិតថ្មីប្លែក ហើយចាប់អារម្មណ៍ គ្រប់ពេលទម្រាំចេញម៉ូដបានមួយៗ។ តែដោយសារវាជាការងារដែលខ្លួនស្រឡាញ់ទោះមានភាពស្មុគស្មាញ និងលំបាកបន្តិចមែន តែវិសាលនៅតែមិនបោះបង់វាចោលឡើយ ។ ស្នាដៃដែលវិសាលចូលចិត្តថ្នែគឺជាប្រភេទសម្លៀកបំពាក់ មនុស្សស្រីទន់ភ្លន់ដែលបង្ហាញពីភាពថ្លៃថ្នូរ ស្អាតឡើងខ្ទង់តែម្តងហើយមានគុណភាពល្អ និងមើលទៅហាក់ដូចជាមានតម្លៃខ្ពស់។

ក្តីប្រាថ្នាដ៏ធំរបស់អ្នកថ្នែម៉ូតវ័យក្មេងម្នាក់នេះគឺចង់ឲ្យសម្លៀកបំពាក់ដែលខ្លួនបានថ្នែជាប្រភេទរ៉ូបរាត្រីសមោស ត្រូវបានចូលរួមនៅក្នុងកម្មវិធីបង្ហាញម៉ូដសម្លៀកបំពាក់ដ៏ល្បីនៅប្រទេសបារាំង គឺកម្មវិធី Haute Couture ។ នៅក្នុងកម្មវិធីនោះរាល់សម្លៀកបំពាក់ដែលបានដើរបង្ហាញសុទ្ធតែមានតម្លៃរាប់ម៉ឺនដុល្លារឯនោះ នេះជាមហិច្ឆតាដែលខ្លួនចង់ឲ្យពិភពលោកបានស្គាល់ពីសមត្ថភាព ក្នុងនាមជាអ្នកថ្នែម៉ូដដែលមានឈាមជ័រជាខ្មែរ ហើយរួមចំណែកធ្វើឲ្យវិស័យថ្នែម៉ូដនៅប្រទេសយើងកាន់តែមានការទទួលស្គាល់ទាំងអស់គ្នាដែរ។

និតា

Talent: Salat Sreylang
Photographer: Mr. Lee
Stylist: Yulianna Bellini
Director: Mr. Tong
Location: Kampong Trach

Talent: Salat Sreylang
Photographer: Mr. Lee
Stylist: Yulianna Bellini
Director: Mr. Tong
Location: Kampong Trach

Talent: Salat Sreylang
Photographer: Mr. Lee
Stylist: Yulianna Bellini
Director: Mr. Tong
Location: Kampong Trach

Talent: Salat Sreylang
Photographer: Mr. Lee
Stylist: Yuliama Belini
Director: Mr. Tong
Location: Kampong Trach

Think Outside The Box

Hang Over

WE ARE ROCKY!

PHOTOGRAPHER: CHAN DEM
TALETNS: VAYUCK , DAYA , KANIKA, DALIS

Hang Over **សិល្បៈថតរូបថ្មីពី** Professional Photographer CHAN DEM

« គិតអ្វីដែលថ្មីហើយប្លែក» នេះជាឃ្លាទីមួយដែលអ្នកជំនាញថតរូប CHAN DEM បានឆ្លើយតបមកកាន់ទស្សនាវដ្តី Sabay Magz បន្ទាប់ពីជួបគ្នានិយាយពីរូបថត ដែលមិត្តអ្នកអានឃើញក្នុងទំព័រនេះ។ ការបង្កើតសិល្បៈនៅក្នុងរូបថតនេះ ហាក់បីដូចជាប្លែកភ្នែកបន្តិចសម្រាប់មិត្តអ្នកអានមួយចំនួន ដោយសារទស្សនៈមិនស្របគ្នារវាងការរួមបញ្ចូលគ្នានូវគំនិត Creative និងសិល្បៈ។

ពាក់ព័ន្ធនឹងចំនុចនេះ លោក CHAN DEM បានបកស្រាយថា៖ « សម្រាប់ខ្ញុំ សិល្បៈគឺនៅមានគ្រប់ទីកន្លែង ខ្ញុំស្រលាញ់សិល្បៈ អីចឹងហើយបានជារូបថតដែលខ្ញុំថតនៅក្នុង Hang Over Concept នេះបង្កប់សិល្បៈនៃការរស់នៅបែបស៊ីវិលីយរបស់យុវវ័យសម័យថ្មី »។

អ្នកជំនាញថតរូបដែលចូលចិត្តធ្វើដំណើរកម្សាន្ត ដើម្បីស្វែងរកគំនិតថ្មីៗ រូបនេះបន្តថា មានទស្សនិកជនខ្លះ គាត់មើលមិនសូវចូលភ្នែកហើយ អ្នកខ្លះទៀតស្រលាញ់រូបថតទាំងអស់នោះនេះ រហូតដល់អ្នកខ្លះ Save រូបទុកមើលក្នុងទូរសព្ទ និងកុំព្យូទ័រថែមទៀតផង។

លោកបន្តថា ធម្មតាទេមិនថារូបថត ឬវត្ថុអ្វីមួយនោះទេ ឲ្យតែមានបង្កប់អត្ថន័យសិល្បៈ គឺមានន័យថា របស់នោះត្រូវបានបង្កើតឡើងលើសពីការគិតសាមញ្ញៗរបស់មនុស្សទូទៅ។ ជាក់ស្តែងក្នុងរូបដែលលើកមកបង្ហាញពេលនេះអីចឹង គឺបង្កប់ពីសិល្បៈមួយជ្រុងនៃភាពហឺហារ របស់ក្មេងសម័យនេះ ។

« អ្វីដែលខ្ញុំធ្វើខ្ញុំចង់បញ្ជាក់ថា ជីវិតយុវវ័យអាចប្រៀបធៀបទៅនឹងដំណើរផ្សងព្រេង ដ៏វិករាយមួយដែលពួកគេអាចស្វែងរកដោយខ្លួនឯងបាន ក្នុងនោះរាប់បញ្ចូលទាំងការបង្កើតគំនិតថ្មី Style Fashion **ចំណេះដឹងថ្មី បទពិសោធន៍ជីវិត និងអ្វីៗជាច្រើនដែលមិនធ្លាប់បានជួបប្រទះ » ។** CHAM DEM **បញ្ជាក់។**

TARA KIM
LITTLE
LOTUS
VINTAGE

Tara Kim ជាជនជាតិខ្មែរអាមេរិកច្នៃម៉ូដសំលៀកបំពាក់ Vintage ដែលទើបតែមានអាយុ២៥ឆ្នាំប៉ុណ្ណោះ ដោយសារការស្រឡាញ់ចូលចិត្តសំលៀកបំពាក់ Vintage និងរសនិយមផ្ទាល់របស់គាត់ ទើបហាង Little Lotus Vintage បានបង្កើតឡើងនៅក្នុងរដ្ឋកាលីហ្វូញ៉ា សហរដ្ឋអាមេរិក។

បច្ចុប្បន្ន Tara គឺជាសមាជិកមួយរូបក្នុងអង្គការមួយឈ្មោះថា «A Cambodia Journey»។ ដោយសារទឹកចិត្តមនុស្សធម៌ចង់ជួយក្មេងអនាថា ដែលរស់លើចិញ្ចើមផ្លូវក្នុងប្រទេសកម្ពុជា កញ្ញាសុខចិត្តយកប្រាក់ចំណេញដែលបានពីការលក់ក្នុងហាង Little Lotus Vintage ធ្វើការបរិច្ចាគដល់មូលនិធិ ដើម្បីជួយដល់ក្មេងអនាថានៅប្រទេសកម្ពុជា។

Tara Kim មានគម្រោងមកប្រទេសកម្ពុជាផ្ទាល់ក្នុងកម្មវិធីសប្បុរសធម៌ក្នុងខែសីហានេះរយៈពេល២សប្តាហ៍ ដើម្បីផ្តល់ជាជំនួយដល់កុមារអនាថា។ ក្រៅពីភាពសប្បុរសធម៌ កញ្ញាក៏បានចូលរួមលើកតម្កើងពីវប្បធម៌ខ្មែរ តាមការច្នៃម៉ូដក្នុងគោលបំណងចង់រក្សានូវវប្បធម៌រុងរឿង របស់ខ្មែរជាកេរមរតកដល់មនុស្សជំនាន់ក្រោយ។

Tara បញ្ជាក់ថា៖ « មូលហេតុដែលខ្ញុំសម្រេចចិត្តដាក់ឈ្មោះ Little Lotus Vintage ដោយសារតែខ្ញុំគិតថាផ្កាឈូក គឺប្រដូចទៅនឹងការរីកលូតលាស់ពីបាតភក់ ចេញពីកន្លែងងងឹតឡើងទៅទីខ្ពស់ដែលភ្លឺត្រចះត្រចង់ និងជាផ្កាបរិសុទ្ធស្អាតក្នុងន័យសាសនាព្រះពុទ្ធរបស់ប្រជាជនខ្មែរ» ។

កូនខ្មែរនៅអាមេរិកលក់សម្លៀកបំពាក់ Vintage រកលុយជួយក្មេងអនាថានៅស្រុកខ្មែរ

PRO PAINTBALL CAMBODIA

សមរភូមិប្រយុទ្ធបាញ់ពណ៌ដែលអ្នកមិនគួរខឹលង

“ នេះជាបទពិសោធន៍ថ្មីជាមួយនឹងកីឡាកម្សាន្ត បាញ់កាំភ្លើងពណ៌ ដែលវាពិតជាអស្ចារ្យខ្លាំងណាស់ព្រោះថាអ្នកធ្លាប់លេងល្បែងប្រភេទនេះតែនៅក្នុងហ្គេមតែប៉ុណ្ណោះតែឥលូវអ្នកមានឱកាសធ្វើជាតួឯកដ៏អង់អាចនៅក្នុងសមរភូមិពិតបានហើយ។

Pro Paintball Cambodia បានបង្កើតឡើងនូវទីកន្លែងកម្សាន្តបែបយុវវ័យថ្មីសម្រាប់អ្នកដែលចូលចិត្តលេងកីឡាបែបភ័យរន្ធត់រត់គេចតាមរយៈការបាញ់កាំភ្លើងពណ៌លើទីវាលដ៏ធំ។ Sabay Magz ឃើញថា Pro Paintball Cambodia មានការគាំទ្រជាខ្លាំងពីស្រទាប់យុវវ័យខ្មែរព្រោះត្រឹមតែបើកដំណើរការបាន ៣ ខែសោះក៏មានកម្មវិធីប្រកួតរកក្រុមខ្លាំងក្នុងសមរភូមិបាត់ទៅហើយដែលមានការចូលរួមពីក្រុមយុវវ័យទាំងប្រុសទាំងស្រីជាច្រើន។ មិនត្រឹមតែលេងសប្បាយហើយសុខភាពល្អនោះទេ ថែមទាំងអ្នកដែលទទួលបានជ័យលាភីឈ្នះបានមេដាយក្រុមខ្លាំងខាងបាញ់កាំភ្លើងពណ៌ និងរង្វាន់លើកទឹកចិត្តដល់ទៅ ៧៥០ ដុល្លារទៀតផង។
ចាប់ពីពេលនេះទៅអ្នកក៏អាចនាំគ្នាជាក្រុមដើម្បីមកប្រកួតគ្នាលេងការបាញ់កាំភ្លើងពណ៌បានយ៉ាងសប្បាយរីករាយដែលក្នុងការលេងអ្នកគ្រាន់តែចំណាយអស់ម្នាក់ ៩ ដុល្លារប៉ុណ្ណោះ គិតទាំងសម្លៀកបំពាក់ និង Paintball ១០០ គ្រាប់។

ព័ត៌មានបន្ថែមសូមចូលទៅកាន់ទំព័រFB របស់ Pro Paintball Cambodia ។ ”

កាន់តែសប្បាយជាមួយការជិះ BUMPER CARS ស៊ើរីថ្មី

Kid City Asia ពិតជាមានកិត្តិយសជាខ្លាំងដែលបាននាំចូលនូវការកម្សាន្តបែបកីឡាទំនើប ។អស្ចារ្យឈានមុខគេនៅប្រទេសកម្ពុជា។ ទីកន្លែងកម្សាន្តដ៏អស្ចារ្យកន្លងមកនោះមានដូចជា Ice Rink ដំបូងគេនៅកម្ពុជា និង Ice Park នៅផ្សារទំនើប Aeon Mall ក៏ដូចជាIndoor Go-Karting និង Laser Tag ឥលូវនេះគឺបានបន្ថែមនូវអ្វីដែលថ្មីកាន់តែសប្បាយរីករាយថែមទៀតសម្រាប់អ្នក។

ពេលនេះ Indoor Bumper Cars មានអ្វីកាន់តែពិសេសលើសពីមុនទៀត ដោយការនាំចូលពីក្រុមហ៊ុនរបស់អ៊ីតាលី Eurogame ដោយ Bumper Cars ទាំងអស់គឺមានស្តង់ដារ និងសុវត្ថិភាពបំផុតហើយអាចលេងបានគ្រប់វ័យ។ វាកាន់តែសប្បាយថែមទៀតជាមួយនឹងបច្ចេកវិទ្យាថ្មីនៃ Bumper Cars ព្រោះវាមានខ្សែក្រវាត់សុវត្ថិភាពរឹងមាំ និងប្រើអាគុយ២ដែលដាក់នៅក្រោមកៅអីឡានខុសពីប្រភេទBumper Cars ពីមុនៗដែលប្រើចរន្តអគ្គិសនីរឺប្រេងសាំង។

ឡាននិមួយៗគឺបំពាក់ដោយ Laser ៣ ពេលដែលបាញ Laser នោះត្រូវឡានណាមួយឡាននោះនឹងវិលវាធ្វើឲ្យការលេងមានភាពសប្បាយរីករាយ មិនធ្លាប់បានលេងពីមុនមកវាត្រូវបានឆ្លងកាត់ការពិសោធជាច្រើនដងដែលអាចធានាបានថា នឹងទទួលបានភាពសប្បាយ និងសុវត្ថិភាពពេលលេង។ Bumper Cars មួយអាចជិះបានមនុស្សធំម្នាក់ និងកូនក្មេងម្នាក់ អ្នកអាចលេងដោយបែងចែកគ្នាជាក្រុមជាមួយគ្រួសារ រីមត្តភ័ក្តិរបស់អ្នកបានដោយមានការកត់ពិន្ទុក្រុមណាជាអ្នកឈ្នះដោយម៉ាស៊ូនស្វ័យប្រវត្តិពេលលេងចប់។ មាន Bumper Cars ចំនួន១២ឡានកំពុងរង់ចាំអ្នក ដូច្នេះនៅចាំធ្វើអីទៀតនាំគ្នាទៅប្រកួតក្នុងសៃរៀនBumper Cars រកអ្នកខ្លាំងទាំងអស់គ្នា។

MAJOR CINEPLEX by cellcard

អបអរសាទរឧបគម្រប់ 1ឆ្នាំ
ដ៏អស្ចារ្យ!

ទិញ 1 ថែម 1

2D 3D 4DX VIP

សម្រាប់តែ
អតិថិជន សែលកាត
ដែលទូទាត់តាមកាត
CELLCARD REWARDS

ចុច #1818# ដើម្បីទទួលបាន
លេខកូដបញ្ចុះតម្លៃ

01 - 31 សីហា

cellcard

04 សីហា | August 2015

Available in DIGITAL 4DX

13 សីហា | August 2015

Available in DIGITAL 4DX

20 សីហា | August 2015

Available in

27 សីហា | August 2015



Available in DIGITAL 4DX

First and Only VIP Screen in Cambodia

Major Cineplex by Cellcard, world class cinema technology.
7 cinema screens with 1 VIP cinema and 1 4DX cinema
together with 13 cosmic bowling lanes and 1 Platinum room.
Setting a new standard for Cambodia.

DIRECT LINE 023 901111

Sponsored by:

cellcard Angkor YAMAHA CIMB BANK Coca-Cola CP

cellcard blu RHYTHM & BOWL

MAJOR CINEPLEX by cellcard

Major Cineplex Cambodia @majorcineplex www.majorcineplex.com.kh AEON MALL FL.2

G-Devith

មុនចូលសិល្បៈ ខ្ញុំជាជាងជួសជុសទូរសព្ទតាមផ្ទះ

G-Devith ៖ « មុនចូលសិល្បៈ ខ្ញុំជាជាងជួសជុសទូរសព្ទតាមផ្ទះ» សម្បុរស កម្ពស់ខ្ពស់ស្រឡះ បូកផ្សំនឹងការលេងខ្លួនស្រដៀងនឹងតារា K-pop ក្រៅស្រុក អ្នកណាៗក៏ដោយមើលតែម៉ាត្លែតប្រាកដជាសន្និដ្ឋានថាតារាចម្រៀងវ័យក្មេង G-Devith ជាកូនអ្នកភ្នំពេញមានជីវភាពធូធារនឹងគេហើយ។ ប៉ុន្តែធាតុពិតតារាចម្រៀង និងកវីនិពន្ធបទភ្លេងរូបនេះ បញ្ជាក់ថាមុនលេចមុខលើវិថីសិល្បៈ ខ្លួនជាអ្នកបញ្ជូលបទភ្លេង និងជាជាងជួសជុសទូរសព្ទតាមដងផ្លូវមួយរូបប៉ុណ្ណោះ។

ប្រវត្តិជាអ្នកធ្វើទូរសព្ទ តើតារាចម្រៀងរូបនេះរៀនបង្កើតបទភ្លេងដោយរបៀបណា?

លោក G.Devith មានឈ្មោះដើម ងួន ចាន់ដេវីត បច្ចុប្បន្ននេះមានអាយុ ២១ឆ្នាំហើយ

លោកមានស្រុកកំណើតនៅខេត្តបាត់ដំបង ជាកូនច្បងក្នុងចំណោមកូនទាំង២នាក់ក្នុងគ្រួសារ។ ដោយសារជីវភាពលំបាកមិនអាចបន្តការសិក្សានៅមហាវិទ្យាល័យបាន ដេវីតត្រូវបង្ខំចិត្តមករៀនជួសជុលទូរសព្ទនៅភ្នំពេញ ក្នុងបំណងមានមុខរបរផ្គត់ផ្គង់ជីវភាពគ្រួសារ និងរកប្រាក់កាសខ្លះដើម្បីប្អូនស្រីបានរៀនឲ្យចប់ចុងចប់ដើម តែចៃដន្យអីមុខរបរកូចមួយនេះមិនអាចឲ្យ Devith សម្រេចតាមបំណងចង់បាន។

ទោះរកប្រាក់មិនបានច្រើនក៏ដោយ Devith នៅតែបន្តមុខរបរនេះដដែល ព្រោះមិនទាន់រកអ្វីដែលល្អប្រសើរជាងនេះបាន។ ដោយសារតែមានកូនចិត្តស្រឡាញ់សិល្បៈ តាំងពីនៅខេត្តធ្វើឲ្យទម្លាប់ដែលអង្គុយស្តាប់ និងចាក់បទចម្រៀងទាក់ម៉ូយតាមរយៈ Speaker លើតុជាងជួសជុសទូរសព្ទរូបនេះ បានធ្វើឲ្យទេពកោសល្យនិពន្ធបទភ្លេង និងតំនិតបង្កើត Beat ថ្មីៗផុសចេញពីក្នុងខ្លួន Devith ដោយមិនដឹងខ្លួនគួបផ្សំ នឹងសមត្ថភាព Rap ដែលមានស្រាប់ធ្វើឲ្យ Devith ផ្លាស់មុខមាត់ថ្មី។

Devith ប្រាប់ Sabay Magz ថា ៖ « មុខរបរដំបូងក្នុងជីវិតខ្ញុំហ្នឹងផ្តល់ជំនាញឲ្យខ្ញុំ ២ គឺជាងជួសជុស និងអ្នកបញ្ជូលភ្លេងទូរសព្ទហើយក៏មិននឹកស្មានថា មុខរបរដែលបានត្រឹមតែចិញ្ចឹមក្រពះនេះ ជំរុញឲ្យខ្ញុំក្លាយជាអ្នកបង្កើតបទភ្លេងថ្មីដែរ »។

ការចេះធ្វើ Beat និងបង្កើតបទភ្លេងថ្មីបានហើយ G-Devith ក៏ចាប់ផ្តើមបង្កើត Channel ផ្ទាល់ខ្លួននៅលើ Youtube ដោយបង្ហោះវីដេអូចម្រៀងដែលជាស្នាដៃដែលខ្លួនបាននិពន្ធ ហើយទទួលបានការចាប់អារម្មណ៍យ៉ាងខ្លាំងពីសមត្ថភាព Rap និងអត្ថន័យចាប់ជួនគ្នាលើទំនុក Rap របស់ដេវីតនៅក្នុងបទ «Live Fast Die Young»។

ដោយសារស្នាដៃពិសេសរបស់ដេវីត បានធ្វើឲ្យតារាចម្រៀងល្បីពេជ្រ សោភា ចាប់អារម្មណ៍ហើយក៏ជួយជ្រោមជ្រែងដេវីតឲ្យបានបញ្ចេញទេពកោសល្យក្នុងវិថីសិល្បៈបន្ថែមទៀត។

ក្រោយមកអ្នកទាំង ២ បានពួតដៃគ្នាសហការផលិតបទចម្រៀងថ្មីៗ ដើម្បីបម្រើអារម្មណ៍អ្នកស្តាប់បានជាច្រើនបទ។ ក្នុងនោះបទដែលមានការគាំទ្រខ្លាំងមានដូចជាបទ កាហ្វេ«១៥០០» «ម៉ាក់ដឹងម៉ាក់រៃ» និង «ពូកូរមែន? »។

រឹតតែពិសេសថែមទៀត សូម្បីតែបទ ប៉ាដឹងប៉ារៃ ដែលបកស្រាយដោយលោកព្រាប សុវត្ថិ ហើយទទួលបានការពេញនិយមខ្លាំងបំផុតនោះក៏ជាស្នាដៃនិពន្ធថ្មីរបស់ G.Devith ដែរ។

ទោះបីបទ Rap មិនមែនជាការពេញនិយមខ្លាំងនៅក្នុងប្រទេសកម្ពុជាក៏ដោយក៏ដេវីតនៅតែបន្តបង្កើតបទចម្រៀងថ្មីជាបន្តបន្ទាប់ព្រោះចង់ចូលរួមចំណែកក្នុងបង្កើតស្នាដៃនិពន្ធថ្មីដែលជាកម្លាំងចិត្តដល់អ្នកនិពន្ធបទភ្លេងទាំងអស់ ឲ្យខិតខំបង្កើតបទចម្រៀងថ្មីទាំងអស់គ្នាដោយចាប់ផ្តើមពីម្នាក់និពន្ធតែមួយបទ ក៏បានដែរ។

និតា

គោជនីយដ្ឋានដែលមានបរិយាកាសថ្មៃប្រឌិតថ្មី និងធ្វើឲ្យអ្នកមានអារម្មណ៍ប្លែកខុសពីគោជនីយដ្ឋានដទៃទៀតនោះគឺ The Forest Dine ។ នៅទីនេះលោកអ្នកអាចទទួលទានជាមួយម្ហូបខ្មែរជាច្រើនមុខ ក្រោមបរិយាកាសបែបធម្មជាតិ ប្រៀបដូចជាកំពុងញ៉ាំអាហារពេលយប់នៅក្នុងព្រៃហើយមានតន្ត្រីកំដរថែមទៀត។

គោជនីយដ្ឋានថ្មីមួយនេះ គឺផ្តោតសំខាន់ទៅលើបរិយាកាសដូចជានៅក្នុងព្រៃពិតៗអីចឹង! បើនិយាយពីមុខម្ហូបវិញ គឺមានម្ហូបខ្មែរជាច្រើនមុខ នៅក្នុងនោះម្ហូបដែលទទួលបានការគាំទ្រច្រើនពីអតិថិជនមានដូចជា ឈុតបុកល្មង ឆាក្តៅ ត្រីបំពងជូរអែម ពិតជាមានរសជាតិឈ្ងុយឆ្ងាញ់មែនទែន លាយឡំជាមួយការតុបតែងហាក់ដូចនៅក្នុងព្រៃមានសុទ្ធតែដើមឈើ ហើយមានសម្លេងទឹកជ្រោះនិងតន្ត្រីប្រគំកំដរយ៉ាងរងំ។

អ្វីដែលពិសេសថែមទៀតនោះគឺ អ្នកអាចជ្រើសរើសស្រា Cocktail បានច្រើនប្រភេទនៅហាងមួយនេះ។ មិនត្រឹមតែមានរសជាតិប្លែកទេ ភាពសិល្បៈនៃការរចនាម្ហូប និងស្រាក្រឡុកក៏ប្លែកដែរ ហើយបើសិនជាបានទៅ សូមកុំភ្លេចសាកនូវរសជាតិ Cocktail ប្រចាំForest ដូចជា Girl On Fire , Forest Corona Margarita, Threesome និងForest Bumble Bee។

ចង់ទទួលទានអាហារពេលយប់ដ៏ Romantic សូមកុំភ្លេចទៅគោជនីយដ្ឋានForest ។ អ្នកអាចស្វែងរកព័ត៌មានពីហាងមួយនេះតាមរយៈគេហទំព័រ Facebook របស់គោជនីយដ្ឋាន Forest ឬក៏ទាក់ទងទូរសព្ទលេខ 023 648 8888 ។

និតា

FOREST
DINE WITH NATURE

បទពិសោធន៍ទទួលទានអាហារក្នុងព្រៃទំនើប

Located in the heart of Phnom Penh's busiest spot, FOREST is Cambodia's First Fine Dining in a wonderful natural environment.

Lot 1, Street National Assembly, Chbar Ampeou, Phnum Penh, Cambodia.

ចង់ភ្លក់អាហារអឺរ៉ុប និងទស្សនាហាងលក់សម្ភារៈពោរពេញដោយសិល្បៈនេ?

The 240

by MAADS

The 240 ជាភោជនីយដ្ឋានម្ហូបអឺរ៉ុបដែលមានទីតាំងនៅទីប្រជុំជនងាយស្រួលស្វែងរក និងមានបរិយាកាសល្អហើយមានបទភ្លេងរហឹមៗ ធ្វើឲ្យធូរស្រាលអារម្មណ៍។ ជាមួយនឹងអាហារអឺរ៉ុបជាច្រើនប្រភេទ តែSabay ចង់ណែនាំអ្នកឲ្យសាកល្បងញ៉ាំ Smoked Salmon Wrap និង Pasta ពេលដែលអ្នកបានទៅដល់ទីនោះ លើសពីនេះទៀតគឺមានតេសជ្ជៈជាច្រើនប្រភេទដែលអ្នកអាចជ្រើសរើសបាន តែអ្វីដែលពិសេសអ្នកត្រូវតែសាកញ៉ាំនូវប្រភេទទឹកក្រឡុកផ្លែឈើរបស់ The 240 ដែលអ្នកនឹងទទួលបានអារម្មណ៍ថាមានជាសុកភាព និងចាប់មាត់តែម្តងខុសពីទឹកក្រឡុកផ្លែឈើដែលអ្នកធ្លាប់បានញ៉ាំពីមុនមក។

នៅទីនេះក៏មានHappy Hour ដែរគឺចាប់ពីម៉ោង៥ល្ងាចដល់ម៉ោង ៧យប់ ដោយគ្រាន់តែហៅប្រភេទបៀរ ឬស្រាអ្វីមួយកែវ អ្នកនឹងទទួលបានអាហារសម្រន់មួយចានfree ភ្លាម។ ក្រៅពីនេះនៅផ្នែកម្ខាងទៀតនៃហាង The 240 ក៏មានលក់នូវសម្ភារៈប្រើប្រាស់ក្នុងផ្ទះ និង lifestyle ជាច្រើនប្រភេទដែលសុទ្ធតែជាម៉ាកមកពីក្រៅប្រទេសជាង ២០ Brand ហើយមានតម្លៃសមរម្យអាចជ្រើសរើសបានតាមចិត្តរបស់អ្នក។ លក្ខណៈពិសេសរបស់ហាងនោះគឺ អ្នកអាចមើលឃើញពីភាពថ្មីប្លែកៗគ្នា ជារៀងរាល់សប្តាហ៍ជាមួយនឹងឥវ៉ាន់ដែលលក់ និងការតុបតែងដោយប្រើសិល្បៈទាក់ទាញជាច្រើន។
អ៊ីចឹងកុំភ្លេចទៅសាកភ្លក់អាហារអឺរ៉ុប និងទិញសម្ភារៈប្រើប្រាស់ប្លែកៗទាំងអស់គ្នានៅThe 240។

The 240 មានអាសយដ្ឋានផ្ទះលេខ#៨៣ ផ្លូវលេខ២៨០ សង្កាត់ដូនពេញ ខណ្ឌដូនពេញ ដែលទទួលបើកបម្រើពីម៉ោង ៩ព្រឹកដល់ម៉ោង៩យប់ ជារៀងរាល់ថ្ងៃ។ដើម្បីព័ត៌មានបន្ថែមសូមចូលទៅកាន់គេហទំព័រFacebook ហើយLike Page របស់ The 240 ។

និតា

EPIC MARGARITA JUNGLE JUICE

ការញ៉ាំជាតិអាល់កុល ក្នុងពេលធ្វើដំណើរកម្សាន្ត ប្រាកដជាមិនល្អទេ ព្រោះគ្រឿងស្រវឹងអាចនាំមកនូវផលអាក្រក់ផ្សេងៗ។ ប៉ុន្តែបើសិនជាអ្នកអាចរៀបចំពេលវេលាសប្បាយរីករាយ ជាមួយមិត្តភ័ក្ត ឬក្រុមគ្រួសារ នៅកន្លែងជាក់លាក់ណាមួយ ពេលស្រវឹងកុំបើកបរ ហើយបើមិនញ៉ាំឲ្យលើសបរិមាណនោះ ភាពរីករាយសើចសប្បាយប្រាកដជាផ្តល់បរិយាសមិនអាចភ្លេចបានឡើយ។

បទពិសោធន៍ថ្មីមួយ ដែល Sabay Magz នឹងលើកយកមកបង្ហាញមិត្តភ័ក្តិទាំងអស់គ្នាពេលនេះ គឺការធ្វើស្រាក្រឡុកដោយខ្លួនឯង។ ដូច្នេះបើមានពិធីជប់លៀង ឬក៏ធ្វើដំណើរកម្សាន្តទៅកន្លែងណាមួយ មិត្តទាំងអស់គ្នាអាចសាកល្បងបាន។ តោះ ! សាកល្បងរៀនធ្វើទាំងអស់គ្នា !

វិធីធ្វើយ៉ាងម៉េច

ដំបូង ត្រូវហាន់ក្រូចឆ្មា ផ្លែម្នាស់ ស្វាយ ក្រូចក្រហម ឪឡឹកជាចំណិតតូចៗល្មម ដាក់លាយចូលគ្នាទៅក្នុងធុងទឹកកក បន្ទាប់មកចាក់ Tequila 14 ដបចូលឲ្យអស់ ហើយចាក់ Peach Schnapps 4ដប និង Triple Sec 4ដបចូលដែរ រួចហើយចាក់ទឹកក្រូចឆ្មាស្រស់ 1ដបជាមួយនឹងទឹកផ្លែក្រូចស្រស់ ៦ដប ចូលជាមួយនឹងទឹកផ្លែម្នាស់ ៦ដបចុងក្រោយចូលជាការស្រេច ពេលនោះអ្នកនឹងទទួលបានស្រា Epic Margarita Jungle Juice ដ៏ឈ្ងុយឆ្ងាញ់ចាប់មាត់បំភ្លេចមិនបាន។ បរិមាណស្រាដែលបានលាយខាងលើនេះ អាចធ្វើបានសម្រាប់កម្មវិធីផ្សេងៗដែលមានមនុស្សចូលរួមច្រើននាក់។

រឿងផ្សំ

- Tequila ១៤ ដប
- Triple Sec ៤ ដប
- Peach Schnapps៤ ដប
- ទឹកក្រូចឆ្មារស្រស់ ១ដប
- ទឹកក្រូចស្រស់ ៤ដំ
- ទឹកផ្លែម្នាស់ ៦ដប
- ផ្លែក្រូចក្រហម ៦ផ្លែ
- ផ្លែស្វាយស្រស់ ៥ ផ្លែ
- ផ្លែម្នាស់ស្រស់ ២ផ្លែ
- ផ្លែឪឡឹកតូចៗ ២ផ្លែ
- ក្រូចឆ្មារ ២០ ផ្លែ

BOOST JUICE CAMBODIA

98% fat free smoothie made with fresh fruit & good-for-you frozen yogurt!

ហាងទឹកផ្លែឈើក្រឡុកសម្រាប់សុខភាព ដែលមានប្រភពមកពីប្រទេសអូស្ត្រាលី ហើយមានប្រវត្តិល្បីល្បាញតាំងពីឆ្នាំ២០០០ និងមានជាង៣០០សាខានៅក្នុងប្រទេសអូស្ត្រាលីហើយជាង៤០០សាខាទៀតនៅជុំវិញពិភពលោក ពេលនេះបានមកដល់ប្រទេសកម្ពុជាហើយ គឺហាង Boost Juice Cambodia ។ នៅទីនេះផ្តល់ជូនលោកអ្នកនូវទឹកផ្លែឈើស្រស់ៗ និងទឹកផ្លែឈើក្រឡុកដែលសុទ្ធសឹងតែជារូបមន្តពិសេសជំនួយដល់សុខភាព មិនមានសារធាតុគីមី និងគ្មានការប្រើស្ករបន្ថែម គឺរសជាតិផ្អែមធម្មជាតិពីផ្លែឈើស្រស់ៗតែម្តង ដែលអ្នកជំងឺទឹកនោមផ្អែមក៏អាចពិសាបានដោយគ្មានការបារម្ភអ្វីទាំងអស់។

ជាមួយរូបមន្តទឹកផ្លែឈើក្រឡុកទាំងអស់ គឺសុទ្ធតែមានអត្ថប្រយោជន៍ផ្សេងៗគ្នា ទៅតាមតម្រូវការរបស់អតិថិជន ដូចជា អ្នករក្សារាងអាចជ្រើសរើសយកប្រភេទ Low Fat Smoothiesដោយមិនបាច់បារម្ភថាធាត់ដោយសារញ៉ាំទឹកផ្លែឈើក្រឡុក រីឯអ្នកដែលហាត់ប្រាណត្រូវការប្រូតេអ៊ីន ច្រើនគួរជ្រើសយកប្រភេទ Super Smoothies ដូចជា Gym Junkie និងEnergy Liftជាដើម។ ពេលណាដែលអ្នកមានអារម្មណ៍មិនល្អស្រួស រីមិនស្រួលខ្លួនអ្នកអាចសាកល្បងញ៉ាំប្រភេទ Fresh Juice និងមានជាប្រភេទ Summer Crushes និង Lean and Greenដែលផ្សំឡើងយ៉ាងពិសេសសម្រាប់សុខភាពអ្នក។

បើស្រឡាញ់សុខភាពត្រូវតែសាកញ៉ាំ ទឹកក្រឡុកផ្លែឈើពី Boost Juice Cambodia បើអ្នកមិនសាកគឺអ្នកមិនដឹងព្រោះBoost Juice គឺមានអ្វីពិសេសលើសពីទឹកក្រឡុកផ្លែឈើទៅទៀត។
Boost Juice Cambodia មានទីតាំងនៅជាន់ផ្ទាល់ដីក្នុងផ្សារទំនើប AEON Mall Cambodia ។

Okha Kith Lyphanna និង លោក Metin Gezer ជាអ្នកនាំចូលនូវយីហោ Boost Juice Cambodia និងសព្វថ្ងៃគឺជាDirector ប្រចាំនៅ Boost Juice Cambodia។

នំបញ្ចុកដុះផ្សិត

គ្រាន់តែឲ្យឈ្មោះនំបញ្ចុកដុះផ្សិតគឺធ្វើឲ្យអ្នកឆ្ងល់ភ្លាមហើយ ចង់ដឹងថាស្អីគេទៅនំបញ្ចុកដុះផ្សិត?
មិនថាមិត្តទាំងអស់គ្នាទេ Sabay Magz ក៏ឆ្ងល់ដែរតែដើម្បីឲ្យ បាត់ឆ្ងល់ក៏សុខចិត្ត ស្វែងរកហើយទៅដល់កន្លែងនំបញ្ចុក ដុះផ្សិតផ្ទាល់ហើយសាក។

នំបញ្ចុកដុះផ្សិតនេះ ពិតជាមានរសជាតិប្លែកជាងនំបញ្ចុក ដែលយើងធ្លាប់ញ៉ាំមែនហើយទឹកស៊ុបជារូបមន្តពិសេសពី គ្រួសារម្ចាស់ហាងផ្ទាល់ព្រោះតាមសម្តី ដែលគាត់បានប្រាប់ មកកាន់ Sabay Magz ថា៖ « លោកប៉ាគាត់ជាចុងភៅ ជំនាញហើយនៅផ្ទះតែងតែចៃ្នម្ហូបថ្មីៗ សម្រាប់ញ៉ាំជុំគ្នាទើប បង្កើតបាននូវនំបញ្ចុកដុះផ្សិតនេះឡើង» ។

នៅក្នុងនំបញ្ចុកដុះផ្សិតនេះមានគ្រឿងផ្សំជាច្រើន ដូចជា សាច់ត្រី បង្គាប្រហិតត្រី សាច់ជ្រូកខ្ទៃ ឈាមជ្រូក និង ផ្សិតចំបើងលាយគ្នា ជាមួយបន្លែត្រកួន ត្រយូងចេក ស្លឹក កាឆាយដែលធ្វើឲ្យចាប់មាត់បំភ្លេចមិនបាន។បន្ថែមពីនេះ អ្នកអាចហៅថែមនូវក្បាលត្រីឆ្តោ ដែលស្រុះក្នុងទឹកស៊ុប បន្ថែមខាងក្រៅទៀតទុកគ្រាន់ញ៉ាំលេងភ្លែមជាមួយនំបញ្ចុក។

នំបញ្ចុកដែលអ្នកបរិភោគក្នុងហាងនេះ គឺធ្វើដោយម្ចាស់ហាង ផ្ទាល់។ រួមជាមួយការតុបតែងទាំងចាន កែវ និងទិដ្ឋភាពក្នុង ហាងធ្វើឲ្យយើងមានអារម្មណ៍ថាមានអនាម័យ និងគួរឲ្យ ចង់មកញ៉ាំម្តងហើយម្តងទៀតអីចឹងកុំភ្លេចទៅសាកញ៉ាំទាំង អស់គ្នាណា !

និតា

Khmer Fungus Noodle
012 922 892 / 077 787 773
ផ្ទះលេខ #១៦E0 ផ្លូវលេខ ២០០
សង្កាត់ចតុមុខ ខណ្ឌដូនពេញ, ភ្នំពេញ

RECOMMENDED BOOK

THE SECRET



ជាស្នាដៃដំបូងបង្អស់ របស់កវីនិពន្ធ Rhonda Byrne ដែលគាត់បានចែក រំលែកបទពិសោធន៍នៃជីវិតពិត របស់ គាត់បន្ទាប់ពីគាត់បានរកឃើញ នូវ អាថ៌កំបាំងពិភពលោក និងយកមក បកស្រាយឲ្យគ្រប់គ្នាបានដឹងពីថាមពល ពិសេសម៉ូាង ដែលធម្មជាតិបានផ្តល់ ឲ្យយើងគ្រប់គ្នាតែមិនបានដឹង ពីវិធីប្រើ។ ដែលក្នុងនោះនឹងលើកយកពី អំណះ អំណាងច្បាស់លាស ពីអ្នកជោគជ័យ ជាច្រើន ក៏ដូចជាអ្នកវិទ្យាសាស្ត្រដូចជា Albert Einstein, Thomas Edison, Napoleon និងPlato ជាដើម ហើយនេះគឺជាលើក ដំបូងដែលអាថ៌កំបាំងនៃពិភពលោកត្រូវបានគាស់កកាយ ហើយ ប្រាប់ពីវិធីដើម្បីទទួលបានរាល់អ្វីដែលអ្នកត្រូវការទាំងអស់ ដោយ គ្មានដែនកំណត់ មិនជឿសាកអាន ល មើលនឹងបានដឹងហើយថាវា អស្ចារ្យប៉ុណ្ណា។

THE BUSINESS FOR 21TH CENTURY



គ្រប់គ្នាប្រាកដជាបានស្គាល់រូចមកហើយ គឺមហាសេដ្ឋីអចលនទ្រព្យ Robert Kiyosaki បន្ទាប់ពីស្នាដៃជោគជ័យមុនៗ នេះជាស្នាដៃថ្មីមួយទៀតដែលលោកចង់ យកមកបង្ហាញ ប្រៀបដូចជាចង្កៀងបំភ្លឺ ដល់អ្នកទៅកាន់វិថីដ៏ជោគជ័យ ថ្មីមួយ ដែលមិនធ្វើការឲ្យគេអស មួយជីវិតទៀត ធ្វើឲ្យអ្នកមើលឃើញឱកាស និងចេះចាប់ យកឱកាសអោយត្រូវនឹងយុគសម័យផងដែរ។ ជឿទេគ្រាន់តែអានហើយអ្នកនឹង មើលឃើញឱកាសជាច្រើនកំពុងចោមរោមអ្នក។ គួរតែឆ្លៀតពេល បន្ថិចចូលខ្លួនទៅមើលថាBusiness សម្រាប់សតវត្សទី២១និងជាស្អី ដើម្បីចាប់ផ្តើមជីវិតដ៏អស្ចារ្យរបស់អ្នក។

THE MAGIC OF THINKING BIG



មនុស្សរាប់លានអ្នកលើពិភពលោក បានធ្វើការផ្លាស់ប្តូរជីវិតរបស់ពួកគេ បន្ទាប់ពីអានសៀវភៅ The Magic Of Thinking Big ពី Dr.David J.Schwartz ដែលជាអ្នកជំនាញខាង ចិត្តសាស្ត្រ ដែលនឹងចូលខ្លួនមកបង្ហាត់ ការគិតរបស់អ្នកអាន ឱ្យមានភាព ទូលំទូលាយជាងមុន។ ជាពិសេស គឺក្នុងការកែប្រែឱ្យប្រសើរ ជាងមុន ទាំងជីវិត ស្នេហា ការងារ និងធ្វើឱ្យ មានសមាធិផ្លូវចិត្ត។ ចាប់ផ្តើមមាគ ជោគជ័យពីក្នុងចិត្តរបស់អ្នក ជាមួយ Magic Of Thinking Big ឥឡូវភ្លាម ទៅ បើអ្នកចង់ផ្លាស់ប្តូររាល់ចំណុចអវិជ្ជមានក្នុងជីវិតរបស់អ្នក។

THE MAGIC OF THINKING BIG



អ្នកណាថាអ្នកមានសុទ្ធតែឆ្លាត ហើយ អ្នកក្រសុទ្ធតែលូង់? ហេតុអ្វីអ្នកមាន ធ្វើការតិច តែបានចំណូលមហាសាល តែអ្នកក្រវិញធ្វើការយ៉ាងច្រើនតែរកអង្ករ ច្រកឆ្នាំងស្ទើរគ្មាន? អាថ៌កំបាំងដែល ជាចម្លើយនឹងត្រូវបានទម្លុះ បង្ហាញ យ៉ាងជាក់ច្បាស់នៅក្នុងសៀវភៅ "How Come That Idiot's Rich and I'm not?" ឬ "អ្នកឡឺកឺបានធ្វើសេដ្ឋី ហេតុអ្វីខ្ញុំក្រ?" ដែលជាស្នាដៃ ជីវប្រវត្តិ ពិតរបស់លោក រ៉ូបឺត សេមីន ដែលជា មហាសេដ្ឋីមានទ្រព្យសម្បត្តិ រាប់រយ លានដុល្លារ និងជាម្ចាស់អចលនទ្រព្យជាង៤០០កន្លែង។ ប៉ុន្តែរ៉ូបឺតជាសេដ្ឋីដ៏ឡឺកឺម្នាក់ដែលគ្រាន់តែផ្ទះរបស់ខ្លួន ក៏គាត់រកមិន ឃើញនៅក្នុងផែនទីដែរ។ គាត់នឹងបង្ហាញគន្លឹះក្នុងការប្រែក្លាយអ្វីៗ ក្នុងខ្លួនអ្នកពីភាពក្រីក្រឲ្យក្លាយជាអ្នកមានតាមបែបសេដ្ឋីឡឺកឺបានដោយ រប៉ៀបណា។ នៅចាំដល់ណាទៀត? នៅចង់ធ្វើការលំបាកដល់ណាទៀត? នៅចង់ក្រដល់ណាទៀត? ឆាប់ស្វែងរកគន្លឹះអាថ៌កំបាំងនៅក្នុងសៀវ ភៅរបស់ រ៉ូបឺត ដែលលក់ដាច់បំផុតក្នុងចំណោមសៀវភៅល្បីៗនៅ ក្នុងសហរដ្ឋអាមេរិច។

Tire Pond

នៃកង់ឡានចាស់ៗ ទៅជាអាងទឹក និងជើងផ្កា

អ្នកមិនធ្លាប់បានចាប់អារម្មណ៍សោះថាយើងអាចយកកង់ឡានដែលចាស់ៗមកច្នៃប្រឌិតប្រាស់បានមកវិញទេ តែពេលនេះអ្នកអាចមានគំនិតច្នៃប្រឌិតថ្មីដោយអាចយកកង់ឡានចាស់មកធ្វើជាអាងទឹកចិញ្ចឹមត្រី ឬ ធើ្វដាំផ្កាលម្អនៅក្នុងសួនរបស់អ្នកបានយ៉ាងស្រស់ស្អាត។

ដំបូងអ្នកត្រូវរាស់ទំហំកង់ឡានដែលអ្នកយកមក ហើយជីកដីតាមទំហំនោះឲ្យរួចស្រេច បន្ទាប់មកយកកាំបិតរ:ចំហៀងកង់ឡានខាង ដែលត្រូវផ្ទាររឡើងលើ បន្ទាប់ពី នេះ សម្រាប់អ្នកដែលស្រឡាញ់ពណ៌ក៏អាច លាបពណ៌បន្ថែមតាមដែលចិត្តចង់ផងដែរ មុនពេលដាក់កង់ឡាននោះទៅក្នុងរណ្តៅដែលបានជីករួច។

ត្រូវក្រាលថង់ប្លាស្ទិកមុនពេលដាក់កង់ឡានចូល។ បើមិនចង់ដាក់ថង់ប្លាស្ទិកទេអ្នកអាចបៀតស៊ីម៉ង់នៅពីក្រោមក៏បាន ជាចុងក្រោយអ្នកអាចចាក់ទឹកចូលឲ្យពេញធើ្វជាអាងក៏បាន ឬ ចាក់ដីចូលទៅធើ្វជាជើងផ្កាក៏បានតាមតម្រូវការចង់បានរបស់អ្នក។

ប្រភព៖ goodhomedesign
ប្រែសម្រួល៖ និតា

Smelly Foot

វិធី3យ៉ាង ដើម្បីបំបាត់ក្លិនជើង

1.Baking Soda
ម្សៅ Baking Soda វាមានឥទ្ធិពលខ្លាំងបំផុត ក្នុងការបំបាត់បាក់តេរីដែលមាននៅក្នុងញើសនៃជើងរបស់យើង។ ដាក់ Baking Soda មួយស្លាបព្រាបាយសម្រាប់រាល់ទឹកក្តៅឧណ្ហៗ1លីត្រ ហើយដាក់ជើងត្រាំក្នុងទឹកនោះរយៈពេល15ទៅ20 នាទីជារឿងរាល់យប់រយៈពេលមួយសប្តាហ៍។ ឬ អ្នកអាចរោយម្សៅBaking Soda នេះទៅក្នុងស្រោមជើង និងស្បែកជើងមុនពេលពាក់ក៏បានដែរ។

2.ប្រេងផ្កាឡាវេនឌ័រ
ប្រេងផ្កាឡាវេនឌ័រ មិនត្រឹមតែមានក្លិនក្រអូបនោះទេ វាថែមទាំងមានមុខងារកម្ចាត់បាក់តេរីផ្សិតទៀតផង ដែលជាចំណែកធ្វើឲ្យជើងធុំក្លិនមិនល្អ។ ដំបូងត្រូវចាក់ប្រេងផ្កាឡាវេនឌ័រ2 ទៅ3តំណក់ទៅក្នុងទឹកក្តៅឧណ្ហ រួចត្រាំជើងពី15ទៅ20នាទី ធើ្វបែបនេះពី2ដងក្នុងរយៈពេលមួយថ្ងៃឲ្យបានរយៈពេល3ឬ4ថ្ងៃនោះអ្នកនឹងឃើញពីលទ្ធផល។

3.ទឹកខ្មេះ
ទឹកខ្មេះមានសារជាតិអាស៊ីដម៉្យាងដែលជួយទប់ស្កាត់មិនឲ្យ ប្រភេទបាក់តេរីដែលបង្កឲ្យជើងមានក្លិនរីកលូតលាស់បាន។ គ្រាន់តែយកទឹកខ្មេះមួយពែងកន្លះដាក់ចូលទៅក្នុងទឹកក្តៅឧណ្ហប្រហែល1លីត្រ ហើយដាក់ជើងត្រាំពី10ទៅ15 នាទី រួចលាងជើងជាមួយសាប៊ូឲ្យបានស្អាតដើម្បីបំបាត់ក្លិនទឹកខ្មេះ។

Smelly Armpit

រូបមន្តបំបាត់ក្លិនភ្លៀក

ក្រូចឆ្មារអាចជួយឲ្យបំបាត់ក្លិនភ្លៀកបានយ៉ាងមានប្រសិទ្ធភាព ព្រោះវាជួយកាត់បន្ថយនូវសារជាតិអាស៊ីដដែលបង្កឲ្យមានមេរោគនិងធុំក្លិននៅភ្លៀក ដោយពុះក្រូចឆ្មារមួយចំណិតហើយច្របាច់យកទឹកក្រូចឆ្មារនោះ យកមកលាបនូវភ្លៀកទុករយៈពេលប្រហែល10នាទី រួចងូតទឹកតែម្តង។ គួរធើ្វបែបនេះមួយថ្ងៃម្តងរហូតដល់បាត់ធុំក្លិនចាំឈប់។
វិធីមួយទៀតនោះគឺគ្រាន់តែហាន់ស្លឹកជីវាន់សុយ ឲ្យបានត្រឹមមួយស្លាបព្រាបាយដាក់ក្នុងកែវ ហើយចាក់ទឹកក្តៅដែលពុះចូលទៅ រួចទុកឲ្យត្រជាក់ចាំញ៉ាំ ព្រោះជីវាន់ស៊ុយត្រូវបានស្គាល់ជារុក្ខជាតិ ដែលមានសមត្ថភាពបំបាត់នូវក្លិនខ្លួនជាច្រើនយ៉ាង។

Source:http://www.top10homeremedies.com/home-remedies/home-remedies-for-foot-odor.html
http://www.besthealthmag.ca/best-you/home-remedies/natural-home-remedies-body-odour#AoLpKmb4lSbpKZxg.97

Smelly Mouth

ក្លិនមាត់អាក្រក់ បណ្តាលមកពីមូលហេតុអ្វីខ្លះ?

ក្លិនមាត់អាក្រក់ អាចជារឿងមួយគួរអោយខ្មាស់ និងពេលខ្លះនាំឱ្យកើតជំងឺថប់បារម្ភទៀតផង។ វាគ្មានអ្វីដែលគួរឱ្យឆ្ងល់នោះទ ក្នុងការប្រើប្រាស់ផលិតផលជាប្រភេទស្ករកៅស៊ូ ទឹកលាងមាត់ និងផលិតផលផ្សេងៗទៀត ដើម្បីបំបាត់បញ្ហាក្លិនមាត់អាក្រក់។ ប៉ុន្តែ ភាគច្រើន ផលិតផលទាំងនេះគ្រាន់តែមានប្រសិទ្ធភាព
បណ្តោះអាសន្នប៉ុណ្ណោះ ព្រោះវាមិនទៅលុបបំបាត់ អ្វីដែលជាមូលហេតុរបស់វាបានទេ។

- អាហារ
ការបំបែកអាហារ ទៅជាបំណែកតូចៗក្នុង និងជុំវិញធ្មេញអាចបង្កើនចំនួនបាក់តេរី និងបណ្តាលឱ្យកើតជាក្លិនអាក្រក់បាន។ ការញ៉ាំអាហារដូចជា ខ្ទឹមបារាំង ខ្ទឹមស និងបន្លែផ្សេងទៀត ក៏អាចបណ្តាលឱ្យមានក្លិនមាត់អាក្រក់ដែរ។ ក្រោយពីអាហារទាំងនេះ ត្រូវបានរំលាយរួច វានឹងចូលទៅក្នុងចន្លោះឈាម
ដឹកនាំទៅសួត និងប៉ះពាល់ដល់ក្លិនមាត់តែម្តង។

- បារី
ការជក់បារី គឺបង្កើតបានជាក្លិនមាត់ ដូចបារីតែម្តង។ អ្នកជក់បារី ក៏ទំនងជាមានជំងឺអញ្ចាញធ្មេញដែលនាំឱ្យមាន ក្លិនមានអាក្រក់ដែរ។កង្វះអនាម័យមាត់ធ្មេញ បើសិនជាអ្នក មិនដុសសម្អាតធ្មេញរាល់ថ្ងៃទេ នោះកម្ទេចទឹកទីអាហារ ដែលសល់ក្នុងមាត់ នឹងបង្កជាក្លិនមានអាក្រក់បាន។ កំណកជាប់ធ្មេញ ដែលមានពណ៌ អាចនឹងបង្កការរលាក នៅអញ្ចាញធ្មេញបាន។ ចំពោះអណ្តាត ក៏អាចជាកន្លែងផ្ទុកបាក់តេរីសម្រាប់បង្កើតក្លិនមាត់មិនល្អបានដែរ។ ចំពោះធ្មេញដែលមិនបានសម្អាតទៀងទាត់ ឬមិនបានដាក់ត្រឹមត្រូវ សុទ្ធតែអាចជាប់កំណកធ្មេញ បង្កក្លិនមាត់បានទាំងអស់។

- សួតមាត់
ទឹកមាត់ នឹងជួយសម្អាតមាត់ លុបបំបាត់កម្ទេចកំទី ដែលបណ្តាលឱ្យមាន ក្លិនមាត់អាក្រក់បាន។ ជំងឺសួតមាត់ អាចនឹងបង្កក្លិនមាត់បាន ព្រោះកង្វះការផលិតទឹកមាត់។ ការសួតមាត់ ជាធម្មតា កើតឡើងនៅពេលកំពុងគេងដែលជាហេតុនាំឱ្យធុំក្លិនមាត់មិនល្អ នៅពេលព្រឹក។ ថ្នាំមួយចំនួន អាចនាំឱ្យកើតជំងឺសួតមាត់ពុំរ៉ែបាន។
ថ្នាំមួយចំនួន អាចបណ្តាលឱ្យមានក្លិនមាត់អាក្រក់ ដោយប្រយោលដែរ តាមរយៈការធ្វើឱ្យសួតមាត់។ ថ្នាំខ្លះទៀត បែរជារំលាយក្នុងខ្លួនមែន តែវាបញ្ចេញជាគីមីរបស់វា ចូលក្នុងផ្លូវដង្ហើមទៅវិញ។

រិជ្ជ:បណ្ឌិត គង់ មនោ
068888900 / 066668899

បក្សចាងបន្ថែមសាខាក្បាច់គុនថ្មី ផ្តល់អារម្មណ៍កម្សាន្តប្លែក

ប្រវត្តិរបស់ហ្គេមនិស្ស័យស្នេហ៍ដាវទេព JX II ត្រូវបានបង្កើតឡើង តាមរយៈរឿងព្រេងបុរាណចិនដ៏យូរលង់ណាស់មកហើយ ដែលនិយាយអំពីការប្រមូលផ្តុំនូវអ្នកគន្ធនិយមក្នុងសម័យសង្គ្រាមឥតឈប់ឈរដើម្បីដណ្តើមយកលេខ១ក្នុងពិភពគុន។

jx2.sabay.com | facebook.com/JXSabay

សេវាកម្សាន្តនេះចាប់ផ្តើមល្បីល្បាញនឹងមានឈ្មោះបោះសម្លេងកាន់តែខ្លាំង បានភាពល្បីល្បាញតាមរយៈការគាំទ្រយ៉ាងខ្លាំងពីសំណាក់អ្នកកម្សាន្តគ្រប់ទិសទី។

កាន់តែពិសេសជាងនេះទៅទៀតនោះ និស្ស័យស្នេហ៍ដាវទេព JXII នឹងធ្វើការបន្ថែមនូវសាខាថ្មីមួយទៀតរបស់បក្សចាងគឺ ចាងកាំបិតស្មៀតដើម្បីផ្តល់ឲ្យការកម្សាន្តកាន់តែមានភាពសម្បូរបែបនឹងកាន់តែសប្បាយរីករាយ ដូច្នេះអ្នកកម្សាន្តទាំងអស់ច្បាស់ជាទទួលអារម្មណ៍ប្លែកជាមួយក្បាច់គុនថ្មីរបស់បក្សចាងកាំបិតស្មៀតក្នុងសេវាកម្សាន្តបែបផ្សងព្រេងល្ពត្តិ៍ចំគេមួយនេះជាក់ជាពុំខាន។

ដូច្នេះសម្រាប់ព័ត៌មានបន្ថែមសូមចូលទៅកាន់ ឬទំនាក់ទំនងតាមរយៈទូរស័ព្ទលេខ ០២៣ ៨៨៣ ០០០ ។

កាន់តែស្រួលហើយឥឡូវ! ទិញសម្ភារៈក្នុង ML ម៉ាស្រួលម៉ង!

សំរាប់អ្នកដែលចូលចិត្តលេង League of Legend ក៏ងាយស្រួលក្នុងការទិញសម្ភារៈដោយមិនចាំបាច់ប្រើ Visa Card ឬ Master Card ដែរ! គ្រាន់តែលោកអ្នកមាន Account Sabay ហើយទិញតាមរយៈ Sabay Coin ជាការស្រេច!

ដូច្នេះប្រិយមិត្តត្រូវបញ្ចូលទឹកប្រាក់ (Sabay Coin) នៅក្នុង Mysabay Account ជាមុនសិន។

ប្រិយមិត្តអាចរកជាវ Sabay Coin តាម Wing, PayGo ពីហាងអ៊ីនធឺណិត និងពីក្រុមហ៊ុន Sabay ។

បន្ទាប់មកប្រិយមិត្តចូលទៅក្នុងហាងអនឡាញ នៅក្នុងនោះដែរលោកអ្នកអាចទិញ Game Card ផ្សេងៗទៀតបានជាច្រើន។ ក៏ប៉ុន្តែសុំលើកយកពីការទិញតាមរយៈ Riot Card ជាមុនសិន!



ជ្រើសរើសកាតណាមួយដែលលោកអ្នកចង់ទិញ ហើយចុចទិញ ។ លោកអ្នកនឹងទទួលបានលេខកូដ Success នៅ Screen បន្ទាប់ ។ លោកអ្នកគ្រាន់តែ Copy លេខកូដទុក រួចចូលទៅកាន់ League of Legend ហើយ Log In Account League of Legend របស់អ្នកភ្លាមទៅ។



ចុចនៅលើ Store នៅផ្នែកខាងលើ Screen ហើយចុចនៅលើបុត្តុង Code ខាងឆ្វេងដៃ



ពេលនោះនឹងឃើញពាក្យ Screen Redeem Code. ហើយបញ្ចូលលេខកូដរបស់អ្នកដែលបានមកពី Mysabay ហើយ Paste រួចចុចពាក្យថា Submit .

.

លោកអ្នកនឹងបានឃើញ នៅ Screen មួយទៀតដែលបានបញ្ជាក់ថា ការបញ្ចូនលេខកូដបានជោគជ័យ ដូច្នេះបញ្ជាក់ថា លោកអ្នកមានទឹកប្រាក់ 5 ដុល្លារ នៅក្នុង Riot Point របស់លោកអ្នក។ ដូច្នេះលោកអ្នកអាចទិញ Item ផ្សេងៗទៀតទៅតាមការចង់បានរបស់លោកអ្នកជាការស្រេច។



សិល្បៈ
SHOW OFF!

ផ្ញើ Art-Work របស់អ្នកតាមរយៈអីម៉ែល : luok.vannarong@cidc.com.kh ។
ក្រុមការងារនឹងជ្រើសរើស Art-Work របស់អ្នកក្នុងករណីសមស្របតាមលក្ខខណ្ឌដែលបានកំណត់។



ប្រធានបទ: ខ្ញុំគឺខ្ញុំ | ប្រភេទ: Doodle Art | សិល្បៈករ: Errandly

ប្រធានបទ: ទិដ្ឋភាពស្រុកស្រែ | ប្រភេទ: Digital Art | សិល្បៈករ: Visoth Kakvei

ព័ត៌មានបន្ថែមសូមចូលទៅកាន់ទំព័រហ្វេសបុក Facebook Sabay Magz : https://www.facebook.com/SabayMagz

sabay.com

YOUR ONE STOP PUBLISHING PARTNER

MOST WIDELY READ KHMER PUBLICATION IN THE UNIVERSE

sabay NEWS

SABAY.TV

sabay magz

sabay MVP

sabay coin

sabay music

Contact Sabay today to publish your content in Cambodia:

pr@sabay.com | 077 777 418